No. 3

ខេត្តសៀមរាប អាជ្ញាធរអប្សរា រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការ
អន្តរជាតិនៃប្រទេសជប៉ុន

# ការសិក្សាស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

# ក្រុងសៀមរាប/អង្គរនៃព្រះរាជាណាចក្រកម្ពុជា

## របាយការណ៍ចុងក្រោយ

## ភាគទី ២ : របាយការណ៍គោល

**ខែមីនា ឆ្នាំ២០០៦**

JICA LIBRARY
1182588 [2]

មជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន
Nippon Koei Co., Ltd
Kokusai Kogyo Co., Ltd

C M O
J R
06-006

ខេត្តសៀមរាប អាជ្ញាធរអប្សរា រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការ
អន្តរជាតិនៃប្រទេសជប៉ុន

# ការសិក្សាស្តីពីផែនការមេសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

## ក្រុងសៀមរាប/អង្គរនៃព្រះរាជាណាចក្រកម្ពុជា

## របាយការណ៍ចុងក្រោយ

## ភាគទី ២ : របាយការណ៍គោល

ខែមីនា ឆ្នាំ២០០៦

មជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន

Nippon Koei Co., Ltd និង
Kokusai Kogyo Co., Ltd

1182588[2]

សមមូលរូបិយវត្ថុ

(អត្រាផ្លូវប្រាក់ផ្លូវការ ឆ្នាំ២០០៤)

១ ដុល្លារអាមេរិក = ៤.០១៦ រៀល

បើគ្មានការផ្តល់ព័ត៌មានជាពិសេសទេ

# កថាមុខ

ដើម្បីឆ្លើយតបទៅនឹងសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលនៃប្រទេសជប៉ុនបានសំរេចធ្វើ "ការសិក្សាអំពីផែនការមេរូមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរក្នុងព្រះរាជាណាចក្រកម្ពុជាប្រកបដោយនិរន្តរភាព" ហើយបានប្រគល់ការសិក្សានេះទៅឱ្យទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ។

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនបានបញ្ជូនក្រុមសិក្សាមួយក្រុមទៅប្រទេសកម្ពុជាពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៦ ដែលដឹកនាំដោយលោកបណ្ឌិត Jinichiro Yabuta នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន ។

ក្រុមសិក្សានេះបានធ្វើការពិភាក្សាជាច្រើន ជាមួយនឹងមន្ត្រីពាក់ព័ន្ធនៃរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងបានធ្វើការអង្កេតផ្ទាល់ក្នុងតំបន់សិក្សា ។ ក្រុមសិក្សាបានធ្វើការសិក្សាបន្ថែមជាច្រើនទៀត និងបានរៀបចំរបាយការណ៍ចុងក្រោយនេះឡើង បន្ទាប់ពីបានវិលត្រឡប់ទៅកាន់ប្រទេសជប៉ុនវិញ ។

ខ្ញុំមានជំនឿថា របាយការណ៍នេះនឹងចូលរួមដល់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព និងដល់ការពង្រឹងទំនាក់ទំនងមិត្តភាពរវាងប្រទេសទាំងពីរ ។

ជាចុងក្រោយ ខ្ញុំសូមកោតសរសើរអស់ពីដួងចិត្តដល់មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងប្រទេសកម្ពុជា ដែលបានចូលរួមសហការយ៉ាងជិតស្និទ្ធក្នុងការសិក្សានេះ ។

ខែមីនា ឆ្នាំ២០០៦

Takashi Kaneko
អនុប្រធាន
ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

*ការសិក្សាអំពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍សៀមរាប/អង្គរប្រកបដោយនិរន្តរភាព*

ខែមីនា ២០០៦

**គោរពជូន :** លោក Takashi Kaneko

អនុប្រធាន

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន

តូក្យូ ជប៉ុន

**លិខិតផ្ញើរ**

***លោក*** Kaneko ***ជាទីគោរព*** :

ខ្ញុំមានក្តីរីករាយបញ្ជូនឱ្យលោកនូវរបាយការណ៍ចុងក្រោយនៃការសិក្សា ស្តីពីផែនការមេរួមសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាពក្នុងព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍ចុងក្រោយនេះមានបីភាគ - ភាគ ទី ១ : សេចក្តីសង្ខេបសម្រាំង ភាគទី ២ : របាយការណ៍គោល និងភាគទី ៣ : របាយការណ៍តាមវិស័យ ។

វត្ថុបុរាណប្រវត្តិសាស្ត្រក្នុងក្រុងសៀមរាប/អង្គរមិនត្រឹមតែជាបេតិកភណ្ឌវប្បធម៌ពិភពលោកប៉ុណ្ណោះទេ តែថែមទាំងជានិមិត្តរូបនៃប្រទេសកម្ពុជា ពោលគឺជាអត្តសញ្ញាណជាតិខ្មែរ។ ជាងនេះ បេតិកភណ្ឌវប្បធម៌ពិភពលោកនេះគឺជាប្រភពដ៏សំខាន់នៃរូបិយវត្ថុបរទេស ។ ដូចនេះ ការខិតខំកែប្រែក្រុងទៅជាក្រុងគំរូលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពខ្ពស់គឺជាការចាំបាច់។ ទោះជាយ៉ាងនេះក៏ដោយ ក្រុងមិនត្រឹមតែមាននិរន្តរភាពសំរាប់តែការទាក់ទាញភ្ញៀវទេសចរមកកំសាន្តបេតិកភណ្ឌប្រវត្តិសាស្ត្រប៉ុណ្ណោះទេ តែផ្ទុយទៅវិញគឺជាក្រុងគំរូ ដែលជានិមិត្តរូបដ៏ល្អនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងសតវត្សរ៍ទី២១។ ការកែសំរួល និងកែលំអជាញឹកញាប់ក្នុងដំណើរការរៀបចំក្រុងគឺជាការចាំបាច់ ប៉ុន្តែត្រូវធ្វើការឆ្លុះបញ្ចាំងពីគតិបណ្ឌិតលើការអភិវឌ្ឍន៍នៃសម័យអង្គរ ហើយការខិតខំនានាដើម្បីបង្កើតបរិយាកាសដែលយកចិត្តទុកដាក់ខ្ពស់ដល់បរិស្ថានអាចជួយក្រុងឱ្យសំរេចគោលដៅក្នុងការបង្កើតក្រុងគំរូ ដែលមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពខ្ពស់ ។

ដើម្បីធ្វើឱ្យសំរេចគោលដៅនេះ វិស័យទេសចរណ៍ដែលកំពុងមានកំណើននៅពេលបច្ចុប្បន្នគួរត្រូវបានកែប្រែឱ្យទៅជាទេសចរណ៍ប្រកបដោយគុណភាព និងមានតុល្យភាពជាងមុន ដោយកាត់បន្ថយបន្ទុកបរិស្ថានធម្មជាតិ។ មានការផ្តល់យោបល់ថា រដ្ឋាបាលកម្ពុជាត្រូវយកចិត្តទុកដាក់ខ្ពស់លើការគ្រប់គ្រងបរិស្ថាន/ក្រុង រួមទាំងការគ្រប់គ្រងការប្រើប្រាស់ទឹក និងការប្រើប្រាស់ដី ដែលជាការងារចាំបាច់ ដើម្បីធ្វើឱ្យសំរេចក្រុងគំរូមួយដែលមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពពិតប្រាកដ ។

ផែនការមេរយៈពេលវែងដែលបានលើកឡើងក្នុងរបាយការណ៍ចុងក្រោយនេះមិនមែនជាផែនការដែលមិនអាចកែប្រែ និងត្រឹមត្រូវគ្រប់ពេលវេលានោះទេ។ ដូចនេះ ការពិនិត្យឡើងវិញ និងការកែសំរួលនឹងត្រូវធ្វើឡើងឱ្យស្របទៅតាមកាលៈ-ទេសៈប្រែប្រួល។ ចំណែក គំរោងអាទិភាពដែលបានស្នើឡើងគួរតែត្រូវបានពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយ និងជាប្រចាំដើម្បី ធ្វើការរៀបចំ និងការអនុវត្តន៍ឱ្យទាន់ពេលវេលា។ ផ្ទុយទៅវិញ មានការផ្តល់យោបល់ថា អាជ្ញាធរខេត្តត្រូវពង្រឹងសមត្ថភាព របស់ខ្លួនដើម្បីត្រួតពិនិត្យតាមដាន ធ្វើផែនការ និងអនុវត្តគំរោងនានា ដោយមានការជួយឧបត្ថម្ភពីស្ថាប័នជំនាញថ្នាក់ជាតិ ដូចជា អាជ្ញាធរអប្សរា និងក្រសួងពាក់ព័ន្ធផ្សេងៗទៀត ។

ឆ្លៀតក្នុងឱកាសនេះ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ទីភ្នាក់ងាររបស់លោក ខេត្តសៀមរាប អជ្ញាធរអប្សរា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអាជ្ញាធរសំខាន់ៗផ្សេងៗទៀតក្នុងរាជរដ្ឋាភិបាលកម្ពុជាចំពោះកិច្ចសហការ និងជំនួយឧបត្ថម្ភ ដែលមិនអាចកាត់ថ្លៃបានដល់ការសិក្សានេះ។

យើងសង្ឃឹមថា របាយការណ៍នេះនឹងចូលរួមដល់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព។

ដោយក្តីគោរពរាប់អានខ្ពង់ខ្ពស់ពីខ្ញុំបាទ។

Jinichiro Yabuta
ប្រធានក្រុមសិក្សា
ក្រុមសិក្សា JICA និងចង្រ្កាមក្រុមហ៊ុន
នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន
Nippon Koei Co., Ltd និង
Kokusai Kogyo Co., Ltd

ទីតាំងខេត្ត និងស្រុកសៀមរាប



## ផែនទីស្រុកសៀមរាប និងទីប្រជុំជននៃស្រុកសៀមរាប




ស្រុកសៀមរាប

តំបន់ទីប្រជុំជននៃស្រុកសៀមរាប



## បញ្ជីអត្ថបទ

### ភាគទី ២ : របាយការណ៍គោល


ទីតាំងខេត្ត និងស្រុកសៀមរាប ---- ii

ផែនទីស្រុកសៀមរាប និងទីប្រជុំជននៃស្រុកសៀមរាប ---- iii

បញ្ជីអត្ថបទ ---- iv

បញ្ជីតារាង និងរូប ---- vi

សេចក្ដីសង្ខេប ---- ១

១. សាវតា ---- ២៣

១.១ គោលបំណងនៃការសិក្សា ---- ២៣

១.២ តំបន់សិក្សា ---- ២៤

១.៣ ដំណើរការនៃការសិក្សា ---- ២៤

១.៤ រចនាសម្ព័ន្ធរបាយការណ៍ចុងក្រោយ ---- ២៨

២. ស្ថានភាព ភាពខ្លាំង និងបញ្ហា ---- ៣១

២.១ ស្ថានភាព ---- ៣១

២.២ ភាពខ្លាំង ---- ៣៣

២.៣ បញ្ហានានា ---- ៣៤

៣. ចក្ខុវិស័យជាយុទ្ធសាស្ត្រ ---- ៤៦

៣.១ គោលបំណង ---- ៤៦

៣.២ សេណារីយូ ---- ៤៦

៣.៣ ក្រុងសៀមរាប/អង្គរនៅឆ្នាំ ២០២០ ---- ៥២

៣.៤ យុទ្ធសាស្ត្រសំរាប់ក្រុងសៀមរាប/អង្គរឆ្នាំ២០២០ ---- ៥៤

៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់ ---- ៦១

៤.១ ទស្សនៈនៃការបែងចែកតំបន់ ---- ៦១

៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់តំបន់ក្រុង ---- ៦៣

៤.៣ យុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់តំបន់ជនបទ/តំបន់បេតិកភណ្ឌ ---- ៦៦

៤.៤ យុទ្ធសាស្ត្រសំរាប់តំបន់បឹងទន្លេសាប ---- ៦៨

៥. យុទ្ធសាស្ត្រតាមវិស័យ ---- ៧០

៥.១ ផែនការអភិវឌ្ឍន៍ដើម្បីឈានទៅសំរេចយុទ្ធសាស្ត្រ ---- ៧០

៥.២ ផែនការអភិវឌ្ឍន៍តាមវិស័យ ---- ៧៨

៦. គំរោង និងកម្មវិធី ---- ១០៧

៦.១ បញ្ជីនៃគំរោង និងកម្មវិធីនានា ---- ១០៧

៦.២ លក្ខណៈវិនិច្ឆ័យ និងដំណើរការកំណត់គំរោង ---- ១១០

៦.៣ កញ្ចប់អភិវឌ្ឍន៍ ---- ១១៥

៧. ការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុ ---------------------------------------------- ១១៧

៧.១ ការគ្រប់គ្រងការអភិវឌ្ឍន៍ —————————————————— ១១៩

៧.២ ហិរញ្ញវត្ថុមូលដ្ឋាន —————————————————— ១២៥

៧.៣ សកម្មភាពដែលត្រូវតែអនុវត្តជាបន្ទាន់ —————————————————— ១៣៤

៨. ការពិនិត្យពីសង្គម និងបរិស្ថាន ---------------------------------------------- ១៣៥

៨.១ ភាពចាំបាច់នៃលក្ខខណ្ឌបរិស្ថាន និងសង្គម —————————————————— ១៣៥

៨.២ ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងសង្គមដែលបានព្យាករណ៍ —————————————————— ១៣៦

៨.៣ ផែនការកាត់បន្ថយផលប៉ះពាល់ពីផែនការមេដែលបានព្យាករណ៍ —————————————————— ១៣៩

៩. គំរោងសាកល្បង ---------------------------------------------- ១៤៧

៩.១ គំរោងសាកល្បង : ការធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង —————————————————— ១៤៧

៩.២ គំរោងសាកល្បង : ការកំណត់ព្រឹត្តិការណ៍ផលិតផលអង្គរ ២០០៥ —————————————————— ១៥៣

១០. ការវាយតំលៃឥទ្ធិពលទេសចរណ៍លើសេដ្ឋកិច្ចក្នុងស្រុក ---------------------------------------------- ១៦១

១០.១ ឥទ្ធិពលនៃការចំណាយរបស់ភ្ញៀវទេសចរលើសេដ្ឋកិច្ចបច្ចុប្បន្ន —————————————————— ១៦១

១០.២ សេចក្តីរំពឹងទៅពេលអនាគត —————————————————— ១៦៤

១១. ក្របខ័ណ្ឌសកម្មភាពសំរាប់ធ្វើផែនការ ---------------------------------------------- ១៧១

១១.១ ក្របខ័ណ្ឌសកម្មភាពសេដ្ឋកិច្ចសង្គម —————————————————— ១៧១

១១.២ ក្របខ័ណ្ឌសកម្មភាពតាមតំបន់ —————————————————— ១៧៨

១១.៣ ក្របខ័ណ្ឌសកម្មភាពសំរាប់វិស័យទេសចរណ៍ —————————————————— ១៨៥

១២. អនុសាសន៍ ---------------------------------------------- ១៩០

ឧបសម្ព័ន្ធ : សេចក្តីសង្ខេបគំរោង និងកម្មវិធីអាទិភាព ---------------------------------------------- ១៩២

U-1 ការកែលំអតំបន់មណ្ឌលក្រុង —————————————————— ១៩៣

U-2 ការលើកកំពស់ចំណេះដឹងបរិស្ថាន —————————————————— ១៩៥

E-2 បការលើកកំពស់ចំណេះដឹងបរិស្ថាន —————————————————— ១៩៦

TO-1 បណ្តាញទេសចរណ៍បេតិកភណ្ឌខ្មែរ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ —————————————————— ១៩៧

TO-3 ការលើកកំពស់គុណភាពទេសចរណ៍តាមរយៈ រដ្ឋ-ឯកជន —————————————————— ១៩៨

A-1 ការអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ —————————————————— ១៩៩

TR-1 ការកែលំអស្ពានពីសម័យបារាំង —————————————————— ២០០

TR-2 បណ្តាញផ្លូវរណប (ដំហាន ១) —————————————————— ២០១

TR-7 ការស្តារបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌឆ្ងាយៗ —————————————————— ២០២

W-3 ការជំនួសបំពង់ទឹកចាស់ៗ —————————————————— ២០៣

W-4 ការសិក្សាជាយុទ្ធសាស្ត្រអំពីការគ្រប់គ្រងធនធានទឹកក្រោមដីនៅអាងស្ទឹងសៀមរាប និងរលួស —————————————————— ២០៤

SD-2 គំរោងអភិវឌ្ឍន៍ក្រុងក្នុងក្រុងសៀមរាប-អង្គរ —————————————————— ២០៥

P-1 គំរោងបំពាក់ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូតជាបន្ទាន់ —————————————————— ២០៧

# បញ្ជីតារាង និងរូប

## បញ្ជីតារាង


តារាង ១ : ការប្រៀបធៀបសេណារីយ៉ូពីរ -------- ៤

តារាង ២ : យុទ្ធសាស្ត្រ និងផែនការអភិបាលតាមវិស័យ : ខ្លឹមសាររួម -------- ៩

តារាង ៣ : ផែនការអភិវឌ្ឍន៍តាមវិស័យ -------- ១២

តារាង ៤ : គំរោង និងកម្មវិធី (១/២) -------- ១៦

តារាង ៥ : គំរោង និងកម្មវិធីដែលបានស្នើឡើង (២/២) -------- ១៧

តារាង ៦ : តារាងសង្ខេបនៃកិច្ចប្រជុំភាគីពាក់ព័ន្ធ -------- ២៦

តារាង ៧ : ទំរង់រូមនៃផែនការមេ -------- ៣០

តារាង ៨ : ការប្រៀបធៀបសេណារីយ៉ូ -------- ៥០

តារាង ៩ : កន្លែងទេសចរណ៍នៅតាមតំបន់ប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍ និងនៅសៀមរាប -------- ៥១

តារាង ១០ : បញ្ហាធ្វើផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ -------- ៦២

តារាង ១១ : យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមវិស័យ : ខ្លឹមសាររួម -------- ៧៤

តារាង ១២ : ការលើកកំពស់ប្រព័ន្ធបង្ហូរទឹកដែលបានស្នើឡើង - ភាគខាងលិច -------- ៩៨

តារាង ១៣ : សំណើរៀបចំការធ្វើសេវាកម្ម -------- ៩៩

តារាង ១៤ : បញ្ជីគំរោង និងកម្មវិធី (១/២) -------- ១០៧

តារាង ១៥ : បញ្ជីគំរោង និងកម្មវិធី (២/២) -------- ១០៧

តារាង ១៦ : គំរោង និងកម្មវិធីអាទិភាព (១/២) -------- ១១២

តារាង ១៧ : គំរោង និងកម្មវិធីអាទិភាព (២/២) -------- ១១៣

តារាង ១៨ : គំរោង និងកម្មវិធីអាទិភាព និងការប៉ាន់ស្មានតំលៃតំបូង -------- ១១៤

តារាង ១៩ : គំរោង និងកម្មវិធីតាមយុទ្ធសាស្ត្រ និងតំបន់ -------- ១១៥

តារាង ២០ : កញ្ចប់អភិវឌ្ឍន៍ -------- ១១៦

តារាង ២១ : អនុសាសន៍សំរាប់កម្មវិធីកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្ត -------- ១២៤

តារាង ២២ : ការប្រៀបធៀបជំរើសប្រភពប្រាក់ចំណូល -------- ១៣១

តារាង ២៣ : សេចក្តីសង្ខេបនៃផលប៉ះពាល់នៃគំរោងគំរោងទាំងអស់ -------- ១៣៦

តារាង ២៤ : ផែនការត្រួតពិនិត្យក្នុងមុនពេលសាងសង់ និងកំពុងសាងសង់ -------- ១៤៥

តារាង ២៥ : បញ្ជីសកម្មភាពក្នុងគំរោងសាកល្បង -------- ១៤៩

តារាង ២៦ : ការពិពណ៌នានៃគំរោងតាំងពិព័រណ៍ផលិតផលអង្គរ២០០៥ -------- ១៥៣

តារាង ២៧ : *ប្រភេទនៃអ្នកទិញសំខាន់សំរាប់ជាការគិតគូររបស់អ្នកតាំងពិព័រណ៍ (តាមប្រភេទអ្នកទិញ)* -------- ១៥៤

តារាង ២៨ : សេចក្តីសង្ខេបនៃអ្នកចូលរួមតាំងពិព័រណ៍នៅក្នុង "ការតាំងពិព័រណ៍ផលិតផលអង្គរ២០០៥" -------- ១៥៥

តារាង ២៩ : ឥទ្ធិពលនៃវិស័យទេសចរណ៍លើសេដ្ឋកិច្ចបច្ចុប្បន្នក្នុងសៀមរាប ២០០៤ -------- ១៦៤

តារាង ៣០ : រយៈពេលស្នាក់នៅជាមធ្យម និងការចំណាយរបស់ភ្ញៀវទេសចរក្នុងមួយនាក់ដោយលំដាប់តំលៃផ្សេងគ្នានៃសណ្ឋាគារ (ដុល្លារ ឆ្នាំ២០០៤) -------- ១៦៥

តារាង ៣១ : ការប្រៀបធៀបនៃការគណនាសាកល្បងនៃឥទ្ធិពលនៃការចំណាយរបស់ភ្ញៀវទេសចរអន្តរជាតិ ១០០០ នាក់ ដោយប្រភេទផ្សេងគ្នា -------- ១៦៦

តារាង ៣២ : សេចក្តីសង្ខេបនៃការប៉ាន់ស្មានផ្សេងៗសំរាប់ធ្វើការគណនាសាកល្បង---------------------------------១៦៩
តារាង ៣៣ : លទ្ធផលនៃការគណនាការធ្វើតេសការជះឥទ្ធិពលលើស្ថេរភាពនៃសមាសភាពផ្សេងគ្នារបស់ភ្ញៀវទេសចរអន្តរជាតិក្នុងឆ្នាំ ២០២០-------------------------------------------------------------------------------------១៧០
តារាង ៣៤ : ផ្ទៃដី និងដង់ស៊ីតេប្រជាជនតាមស្រុក (ឆ្នាំ២០០៤) ------------------------------------------- ១៧២
តារាង ៣៥ : ប្រជាជនតាមស្រុកក្នុងខេត្តសៀមរាបនៅឆ្នាំ២០០១ និងឆ្នាំ២០០៤ ----------------------------------- ១៧៣
តារាង ៣៦ : ការព្យាករណ៍ចំនួនប្រជាជនតាមស្រុក -----------------------------------------------------------១៧៥
តារាង ៣៧ : ចំនួនប្រជាជនក្នុងស្រុកសៀមរាប ----------------------------------------------------------------១៧៦
តារាង ៣៨ : ការគណនាបឋមអំពីរចនាសម្ព័ន្ធការងារក្នុងខេត្ត និងស្រុកសៀមរាប ------------------------------- ១៧៧
តារាង ៣៩ : ក្របខ័ណ្ឌសកម្មភាពសំរាប់ចំនួនប្រជាជននៃស្រុកសៀមរាប (១/២) ----------------------------------១៨២
តារាង ៤០ : ក្របខ័ណ្ឌសកម្មភាពសំរាប់ចំនួនប្រជាជននៃស្រុកសៀមរាប (២/២) --------------------------------- ១៨៣
តារាង ៤១ : ចំនួន និងទីតាំងសណ្ឋាគារ និងផ្ទះសំណាក់ក្នុងស្រុកសៀមរាប -------------------------------------១៨៨

## បញ្ជីរូប

រូបទី ១ : ការបែងចែកតំបន់សៀមរាប -----------------------------------------------------------------------៨
រូបទី ២ : គោលបំណងនៃការសិក្សា-------------------------------------------------------------------------២៤
រូបទី ៣ : រចនាសម្ព័ន្ធស្ថាប័ន-----------------------------------------------------------------------------២៥
រូបទី ៤ : ក្របខ័ណ្ឌពេលវេលានៃការសិក្សា -------------------------------------------------------------២៧
រូបទី ៥ : រចនាសម្ព័ន្ធរបាយការណ៍ (១) -----------------------------------------------------------------២៨
រូបទី ៦ : រចនាសម្ព័ន្ធរបាយការណ៍ (២) ---------------------------------------------------------------- ២៩
រូបទី ៧ : របាយនៃតំបន់ដែលបានបង្កើតឡើង និងភូមិនានាក្នុងខេត្តសៀមរាប ------------------------------៣១
រូបទី ៨ : សៀមរាបមើលពីលំហ -------------------------------------------------------------------------៣៣
រូបទី ៩ : សមាសភាពនៃភ្ញៀវទេសចរតាមកំរិតនៃតំលៃសណ្ឋាគារនៅឆ្នាំ ២០០៤ -----------------------------៣៥
រូបទី ១០ : រមណីយដ្ឋានអង្គរក្នុង និងក្រៅស្រុកសៀមរាប ------------------------------------------------៣៦
រូបទី ១១ : ការប៉ាន់ស្មានរចនាសម្ព័ន្ធនៃការចំណាយរបស់ភ្ញៀវទេសចរក្នុងមួយថ្ងៃក្នុងមួយជើង ----------------------៣៨
រូបទី ១២ : ធនធានទឹកលើដីនៅសៀមរាប------------------------------------------------------------- ៤០
រូបទី ១៣ : ការប្រែប្រួលនៃចំនួនភ្ញៀវទេសចរតាមរដូវនៅសៀមរាប ------------------------------------------៤១
រូបទី ១៤ : គុណភាពទឹកក្នុងស្ទឹងសៀមរាប ----------------------------------------------------------------៤២
រូបទី ១៥ : ការស្ទះចរាចរណ៍នៅផ្លូវកែងនៃផ្លូវជាតិលេខ ៦ និងមហាវិថីស៊ីវុត្ថា -----------------------------------៤២
រូបទី ១៦ : ចំណែកនៃការចំណាយថវិកាដែលប្រមូលបានពីការចូលទស្សនា----------------------------------- ៤៤
រូបទី ១៧ : រចនាសម្ព័ន្ធបញ្ហានៅសៀមរាប-------------------------------------------------------------- ៤៥
រូបទី ១៨ : កំណើនភ្ញៀវទេសចរនៅតាមតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រសំខាន់ៗក្នុងតំបន់អាស៊ីអាគ្នេយ៍ ------------------ ៤៨
រូបទី ១៩ : ការព្យាករណ៍ចំនួនប្រជាជន---------------------------------------------------------------- ៤៩
រូបទី ២០ : យុទ្ធសាស្ត្រសំរាប់សៀមរាប/អង្គរ ឆ្នាំ២០២០ ----------------------------------------------- ៥៤
រូបទី ២១ : ការបែងចែកតំបន់សៀមរាប ---------------------------------------------------------------- ៦១
រូបទី ២២ : ស្ថានភាពតំបន់នៅសៀមរាបនៅពេលបច្ចុប្បន្ន និងអនាគត---------------------------------------- ៦២

រូបទី ២៣ : ការពង្រីកតំបន់ក្រុងដោយផ្អែកលើទស្សនៈក្រុងទំនើប ---- ៦៤

រូបទី ២៤ : ទស្សនៈសំរាប់ធ្វើផែនការសំរាប់តំបន់ក្រុង ---- ៦៦

រូបទី ២៥ : ទស្សនៈសំរាប់ធ្វើផែនការក្នុងតំបន់ជនបទ/បេតិកភណ្ឌ ---- ៦៨

រូបទី ២៦ : ទស្សនៈសំរាប់ធ្វើផែនការសំរាប់តំបន់បឹងទន្លេសាប ---- ៦៩

រូបទី ២៧ : ឌីជ្យាក្រាមលំហូរអំពីការអភិវឌ្ឍន៍ ---- ៧៧

រូបទី ២៨ : ចំណាត់ថ្នាក់តំបន់ ---- ៧៨

រូបទី ២៩ : ផែនការរួមសំរាប់គំរោងកែលំអតំបន់ផ្សារចាស់ ---- ៧៩

រូបទី ៣០ : ពង្រាងផែនការប្រើប្រាស់ដី ---- ៨០

រូបទី ៣១ : គោលដៅ យុទ្ធសាស្ត្រវិធី និងលំដាប់កម្មវិធី ---- ៨២

រូបទី ៣២ : យុទ្ធសាស្ត្រ និងការគ្រប់គ្រងបរិស្ថាននៅពេលបច្ចុប្បន្ន និងអនាគត ---- ៨៣

រូបទី ៣៣ : តំបន់ និងបណ្តាញរមណីយដ្ឋានអង្គរផ្សេងៗ ---- ៨៥

រូបទី ៣៤ : គោលបំណង យុទ្ធសាស្ត្រ មជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ និងគំរោង/កម្មវិធីផ្សេងៗ ---- ៨៦

រូបទី ៣៥ : ការវិវត្តន៍ផ្នែកទីផ្សារ (គោលគំនិតគំរូ) ---- ៨៧

រូបទី ៣៦ : បណ្តាញផ្លូវសំខាន់ៗ ---- ៨៨

រូបទី ៣៧ : ផ្លូវ TR-2 (ជំហាន ១) ---- ៨៨

រូបទី ៣៨ : ផ្លូវ TR-3 (ជំហាន ២) ---- ៨៨

រូបទី ៣៩ : ផ្លូវ TR-4 (ជំហាន ៣) ---- ៨៩

រូបទី ៤០ : ផ្លូវ TR-5 (ជំហាន ៤) ---- ៨៩

រូបទី ៤១ : បណ្តាញផ្លូវទៅកាន់រមណីយដ្ឋានឆ្ងាយៗ (TR-7) ---- ៨៩

រូបទី ៤២ : ផ្លូវឡានក្រុងដែលបានស្នើឡើង និងតំបន់ហាមឃាត់ឡានឯកជន ---- ៩០

រូបទី ៤៣ : ការកំណត់ដំបូងលើការប្រើប្រាស់ធនធានទឹក ---- ៩១

រូបទី ៤៤ : កម្មវិធីពេលវេលា និងសមត្ថភាពនៃការអភិវឌ្ឍន៍តាមជំហាន ---- ៩១

រូបទី ៤៥ : លំដាប់នៃគំរោង/កម្មវិធី ---- ៩២

រូបទី ៤៦ : ចំនួនសំណល់ និងវិធានការកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ ---- ៩៣

រូបទី ៤៧ : យុទ្ធសាស្ត្រសំរាប់ពង្រីកក្រុមគោលដៅ ---- ៩៤

រូបទី ៤៨ : គោលគំនិតនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹងដែលបានស្នើឡើង ---- ៩៤

រូបទី ៤៩ : ប្រព័ន្ធបង្ហូរទឹកបច្ចុប្បន្ន ---- ៩៦

រូបទី ៥០ : គោលបំណង/ម៉ាទ្រីកអន្តរាគមន៍ ---- ៩៧

រូបទី ៥១ : ការលើកកំពស់ប្រព័ន្ធបង្ហូរទឹកដែលបានស្នើឡើង : ផ្នែកខាងលិច ---- ៩៨

រូបទី ៥២ : ការគ្រប់គ្រងសំណល់រាវដែលបានស្នើឡើង ---- ៩៩

រូបទី ៥៣ : សំណើបួងនៃប្រព័ន្ធសំណល់រាវ ---- ១០០

រូបទី ៥៤ : លំដាប់នៃការអនុវត្តន៍គំរោង ---- ១០១

រូបទី ៥៥ : សេណារីយ៉ូរួមសំរាប់វិស័យអគ្គីសនី ---- ១០៣

រូបទី ៥៦ : ការប៉ាន់ស្មានពីតំរូវការ និងការផ្គត់ផ្គង់អគ្គីសនី ---- ១០៤

រូបទី ៥៧ : ផែនការបែងចែកអគ្គីសនីឆ្នាំ ២០០៤ ---- ១០៤

រូបទី ៥៨ : ផែនការបែងចែកអគ្គីសនីឆ្នាំ ២០១២ ---------------------------------------------------------------------------១០៤

រូបទី ៥៩ : ផែនការបែងចែកអគ្គីសនីឆ្នាំ ២០២០---------------------------------------------------------------------------១០៥

រូបទី ៦០ : លំដាប់នៃការអភិវឌ្ឍន៍រហូតដល់ឆ្នាំ ២០២០ ----------------------------------------------------------------១០៦

រូបទី ៦១ : ដំណាក់កាលទាំង ៤ នៃការអភិវឌ្ឍន៍រហូតដល់ឆ្នាំ ២០២០ --------------------------------------------------- ១១១

រូបទី ៦២ : បញ្ហា និងមូលហេតុនៃបញ្ហាទាក់ទងនឹងរដ្ឋបាលមូលដ្ឋាននៅថ្នាក់ខេត្ត ------------------------------------ ១២២

រូបទី ៦៣ : ពង្រាងរចនាសម្ព័ន្ធរបស់គណៈកម្មការអភិវឌ្ឍន៍ខេត្ត ------------------------------------------------------ ១២២

រូបទី ៦៤ :តំបន់ការពារវប្បធម៌ក្នុងតំបន់សៀមរាបអង្គរ ----------------------------------------------------------------១៤០

រូបទី ៦៦ : គោលគំនិតនៃគំរោងសាកល្បង --------------------------------------------------------------------------------១៤៨

រូបទី ៦៧ : ចំនួនអ្នកចូលទស្សនាការតាំងពិព័រណ៍ ---------------------------------------------------------------------១៥៦

រូបទី ៦៨ : រចនាសម្ព័ន្ធចំណាយរបស់ភ្ញៀវទេសចរក្នុងខេត្តសៀមរាបនៅឆ្នាំ ២០០៤ -----------------------------------១៦២

រូបទី ៦៩ : រចនាសម្ព័ន្ធនៃការជះឥទ្ធិពលលើសេដ្ឋកិច្ចដែលកើតពីការចំណាយរបស់ភ្ញៀវទេសចរនៅសៀមរាបឆ្នាំ ២០០៤----- ១៦៣

រូបទី ៧០ : ចំនួននៃភ្ញៀវទេសចរបែងចែកតាមកំរិតតំលៃស្នាក់នៅក្នុងសណ្ឋាគារនៅឆ្នាំ ២០០៤ ---------------------------១៦៧

រូបទី ៧១ : ការប៉ាន់ស្មានរបាយភ្ញៀវទេសចរតាមតំលៃសណ្ឋាគារសំរាប់ "ករណីជំរើសទី ២ : សមាសភាពភ្ញៀវ ទេសចរ ដែលមានកំរិតចំណាយខ្ពស់ " នៅឆ្នាំ ២០២០------------------------------------------------------------------------១៦៨

រូបទី ៧២ : ស្រុកទាំង ១២ និងរបាយប្រជាជនក្នុងខេត្តសៀមរាប------------------------------------------------------- ១៧១

រូបទី ៧៣ : ទីតាំងនៃកន្លែងតាំងទីលំនៅថ្មី និងភូមិនានាក្នុងខេត្តសៀមរាប ------------------------------------------ ១៧២

រូបទី ៧៤ : កំណើនប្រជាជននៅស្រុកសៀមរាប ----------------------------------------------------------------------------១៧៦

រូបទី ៧៥ : កំណើនការងារក្នុងស្រុកសៀមរាប ----------------------------------------------------------------------------១៧៨

រូបទី ៧៦ : តំបន់សំខាន់ៗពីរ និងបណ្តាញផ្លូវដឹកជញ្ជូនក្នុងប្រទេសកម្ពុជា --------------------------------------------១៧៩

រូបទី ៧៧ : ដង់ស៊ីតេប្រជាជននាពេលបច្ចុប្បន្ន ២០០៤ ------------------------------------------------------------------១៨០

រូបទី ៧៨ : ដង់ស៊ីតេប្រជាជន ឆ្នាំ ២០១២-----------------------------------------------------------------------------------១៨១

រូបទី ៧៩ : ដង់ស៊ីតេប្រជាជន ២០២០) ---------------------------------------------------------------------------------------១៨១

រូបទី ៨០ : ពង្រាងផែនការប្រើប្រាស់ដីធ្លី ----------------------------------------------------------------------------------១៨៥

រូបទី ៨១ : ចំនួនអ្នកទេសចរក្នុងខេត្តសៀមរាបពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០២០ ------------------------------------------១៨៦

រូបទី ៨២ : តំរូវការបន្ទប់សណ្ឋាគារ និងផ្ទះសំណាក់ផ្អែកតាមការព្យាករណ៍ដោយមានអន្តរាគមន៍ពី គោលនយោបាយ ២០០៥-២០២០ ------------------------------------------------------------------------------------------------------១៨៧

# សេចក្ដីសង្ខេប

## ១. សាវតា

រាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានឯកភាពគ្នាលើវិសាលភាពការងារសំរាប់ការសិក្សាផែនការមេរួមមួយ ដើម្បីអភិវឌ្ឍក្រុងសៀមរាប/អង្គរប្រកបដោយ និរន្តរភាពក្នុងព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤ បន្ទាប់ពីទទួលស្គាល់តំរូវការចំពេងសំរាប់ផែនការមេរួម ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន សាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ និងរក្សាគុណភាពបរិស្ថាន និងធនធានទេសចរណ៍នៅក្នុងក្រុងសៀមរាប/អង្គរតាមចក្ខុវិស័យយូរអង្វែង។

របាយការណ៍ចុងក្រោយ ដែលនឹងត្រូវបញ្ជូនចេញនៅខែមីនាឆ្នាំ២០០៦ គឺជាការចងក្រងលទ្ធផលនៃការសិក្សាសំរាប់បង្កើតផែនការមេ។

### ១.១ គោលបំណងនៃការសិក្សា

*ការសិក្សានេះមានគោលបំណងដើម្បី :*

(១) រៀបចំផែនការមេរួមមួយសំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរ រយៈពេលវែងប្រកបដោយនិរន្តរភាព ដើម្បីធ្វើឱ្យសំរេចនូវតុល្យភាពសមស្របមួយរវាងឧស្សាហកម្មទេសចរណ៍ បរិស្ថានក្រុង និងសមត្ថភាពស្ថាប័ន

(២) ស្នើឱ្យមានវិធានការមួយចំនួនក្នុងគោលដៅជំរុញ និងពង្រីកសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការអភិវឌ្ឍន៍ទេសចរណ៍ដែលជាផ្នែកមួយនៃផែនការមេរួមនេះ និង

(៣) លើកកំពស់ការផ្ទេរបច្ចេកទេសឱ្យសមភាគីកម្ពុជា ក្នុងគោលដៅពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន និងសហគមន៍។

### ១.២ តំបន់សិក្សា

តំបន់សិក្សាគ្របដណ្តប់ស្រុកសៀមរាប ដោយយកចិត្តទុកដាក់លើតំបន់ក្រុង និងពង្រីកទៅកាន់តំបន់ពាក់ព័ន្ធផ្សេងទៀតនៃស្រុកសៀមរាបដោយមានគោលដៅសិក្សាសេដ្ឋកិច្ចមូលដ្ឋាន។

### ១.៣ ដំណើរការនៃការសិក្សា

**ក្របខ័ណ្ឌពេលវេលានៃការសិក្សា :** ក្រុមសិក្សាធ្វើការសិក្សានៅក្នុងអំឡុងពេលពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៦ ។

**រចនាសម្ព័ន្ធស្ថាប័ន :** ខេត្តសៀមរាប និងអាជ្ញាធរអប្សរាគឺជាទីភ្នាក់ងារសមភាគីជាមួយក្រុមសិក្សារបស់ JICA ។ មន្ត្រីសមភាគីចំនួន១៣នាក់ពីខេត្តសៀមរាប និងអាជ្ញាធរអប្សរាត្រូវបានជ្រើសឱ្យចូលរួមសហការការងារជាមួយសមាជិកក្រុមសិក្សា JICA ។

**យន្តការសំរបសំរួលសំរាប់ការសិក្សា :** កិច្ចប្រជុំអន្តរក្រសួងថ្នាក់ជាតិត្រូវបានរៀបចំឡើង ដើម្បីចែករំលែកព័ត៌មាននិងសំរាប់ពង្រឹងការងារសំរបសំរួលរវាងក្រសួងពាក់ព័ន្ធ។ គណៈកម្មការដឹកនាំការសិក្សានៅថ្នាក់ខេត្តត្រូវបានបង្កើតឡើង ដើម្បីពិគ្រោះយោបល់ជាមួយក្រុមសិក្សា ដើម្បីធានាឱ្យមានភាពរលូនក្នុងការអនុវត្តន៍ការសិក្សា និងប្រើប្រាស់លទ្ធផលនៃការសិក្សា

ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**នីតិវិធីការនៃការចូលរួមរបស់ប្រជាជន :** ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រដោយមានការចូលរួមពីប្រជាជនតាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ ។ ការចូលរួមទាំងនេះធ្វើឡើង តាមរយៈកិច្ចប្រជុំភាគីពាក់ព័ន្ធចំនួន៤ដងដើម្បីផ្សព្វផ្សាយព័ត៌មាន និងផ្លាស់ប្តូរគំនិតយោបល់ក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗ ដូចជា ប្រជាជន ផ្នែកសាធារណៈ ផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ។

## ១.៤ រចនាសម្ព័ន្ធរបាយការណ៍ចុងក្រោយ

របាយការណ៍ចុងក្រោយនេះមាន ៣ ភាគ ដែលមានខ្លឹមសារដូចខាងក្រោម ។

ភាគទី ១ : សេចក្តីសង្ខេបសម្រាំង

ភាគទី ២ : របាយការណ៍គោល

ភាគទី ៣ : របាយការណ៍តាមវិស័យ

# ២. ស្ថានភាព ភាពខ្លាំង និងបញ្ហា

## ២.១ ស្ថានភាព

សៀមរាបគឺជាទីក្រុងបុរាណនៃវង្សសម័យអង្គរអស់រយៈពេលប្រមាណជា ៦៥០ ឆ្នាំ ចាប់តាំងពីដើមសតវត្សរ៍ទី៩ ។ រង្វសម័យនោះសម្បូររុងរឿង ដែលមានប្រព័ន្ធធារាសាស្ត្រទំនើបសម័យបុរាណ ដែលប្រព័ន្ធទាំងនោះបានប្រើប្រាស់របបទឹកឡើងនៃបឹងទន្លេសាប ។ អាស្រ័យហេតុនេះ សៀមរាបតំណាងប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែររហូតដល់ពេលបច្ចុប្បន្ន ។

បន្ទាប់ពីប្រទេសមានសន្តិភាព ចំនួនភ្ញៀវទេសចរបរទេសកាន់តែច្រើនឡើងៗមកទស្សនាសៀមរាប ។ មានការប៉ាន់ស្មានថា វិស័យទេសចរណ៍បង្កើតការងារប្រមាណជា ៥៥.០០០ ដែលការនេះមានសារៈសំខាន់សំរាប់ប្រទេសយ៉ាងខ្លាំង ។

## ២.២ ភាពខ្លាំង

បើប្រៀបធៀបជាមួយនឹងតំបន់ដទៃទៀតនៅក្នុងប្រទេស ស្រុកសៀមរាបមានចំណុចខ្លាំងបីដូចខាងក្រោម :

- ប្រាសាទអង្គរគឺជាបេតិកភណ្ឌវប្បធម៌សំខាន់បំផុតរបស់ប្រទេស និងជាបេតិកភណ្ឌពិភពលោក
- លទ្ធភាពងាយស្រួលក្នុងការធ្វើដំណើរតាមផ្លូវអាកាស ផ្លូវទឹក និងផ្លូវដី
- ស្រុកសៀមរាបបានទទួលការគាំទ្រខាងគោលនយោបាយពីរដ្ឋាភិបាលថ្នាក់ជាតិ ដូចជា អាជ្ញាធរដែលជាសេនាធិការដ៏រឹងមាំ ដើម្បីការពារប្រាសាទអង្គរ និងផ្តល់ការគាំទ្រខាងបច្ចេកទេសសំរាប់ការអភិវឌ្ឍន៍ក្រុង ។

## ២.៣ បញ្ហា

ស្រុកសៀមរាបបានប្រឈមមុខនឹងបញ្ហា ៦ ដូចខាងក្រោម :

### បញ្ហាទី ១ : ការពឹងផ្អែកហួសហេតុលើទេសចរណ៍ប្រមូលផ្តុំ / ទេសចរណ៍បរិមាណ

លក្ខណៈទេសចរណ៍នៅសៀមរាបគឺជាប្រភេទទេសចរណ៍ដែលមានការស្នាក់នៅរយៈពេលខ្លី ពោលគឺប្រភេទទេសចរណ៍ប្រមូលផ្តុំ ។ ភ្ញៀវទេសចរជាច្រើនទស្សនាសៀមរាបជាក្រុម ដែលចំណាយពេលស្នាក់នៅសៀមរាបតែពីរ ឬបីថ្ងៃប៉ុណ្ណោះ ។ ភ្ញៀវទេសចរទាំងនោះទស្សនាសៀមរាបក្នុងរយៈពេលមួយកំណត់នៅរដូវប្រាំង ដែលមានគោលបំណងទស្សនារមណីយដ្ឋាន

អង្គរមួយគត់។ ភ្ញៀវទេសចរភាគច្រើនមិនមកទស្សនាសៀមរាបម្តងទៀតឡើយ។ ភ្ញៀវទាំងនោះមិនបានទស្សនារមណីយដ្ឋានល្អជាច្រើនទៀត ដែលស្ថិតនៅឆ្ងាយពីសៀមរាបឡើយ។ ប្រភេទទេសចរណ៍ដូចនេះនាំមកនូវកំណើនបន្ទុកបរិស្ថាន ផ្តល់ផលប្រយោជន៍តិចតួចដល់មូលដ្ឋាន និងមានទំនាក់ទំនងតិចតួចជាមួយនឹងវប្បធម៌ក្នុងស្រុក។

**បញ្ហាទី ២ : ផលប្រយោជន៍តិចតួចដល់សេដ្ឋកិច្ចមូលដ្ឋាន**

លក្ខណៈនៃទេសចរណ៍បរិមាណដែលបានរៀបរាប់ខាងលើហាក់បីដូចជាផ្តល់ផលប្រយោជន៍តិចតួចដល់សេដ្ឋកិច្ចមូលដ្ឋាន។ មានសក្តានុពលផ្សេងៗទៀតដើម្បីបន្ថែមផលប្រយោជន៍ដល់មូលដ្ឋាន ពោលគឺតាមរយៈពង្រីកការចំណាយរបស់ភ្ញៀវទេសចរ ដោយបង្កើតឱ្យមានជម្រើសទេសចរណ៍ និងដោយរក្សាទុកប្រាក់ចំណាយបានពីទេសចរណ៍នៅមូលដ្ឋាន។

**បញ្ហាទី ៣ : បរិស្ថាន និងសោភ័ណភាពក្រុងមិនល្អ**

ភ្ញៀវបុគ្គលសាមញ្ញម្នាក់ៗយល់ឃើញថា វិថីសំខាន់ៗក្នុងក្រុងពុំមានសុវត្ថិភាពគ្រប់គ្រាន់សំរាប់ដើរកំសាន្តឡើយ។ ភ្ញៀវទេសចរជាច្រើននិយមត្រឡប់ចូលសណ្ឋាគារវិញ បន្ទាប់ពីទស្សនារមណីយដ្ឋានអង្គរ។ មានភាពចន្លោះដ៏ធំរវាងរមណីយដ្ឋានអង្គរដ៏អស្ចារ្យ និងក្រុងដែលគ្មានការទាក់ទាញ។ ទេសចរណ៍គុណភាពមិនអាចមាននិរន្តរភាពឡើយ ប្រសិនបើគ្មានបរិយាកាសក្រុងប្រកបដោយគុណភាពខ្ពស់ ពោលគឺក្រុងដែលមិនបំផ្លាញដល់បរិយាកាសអង្គរ។

**បញ្ហាទី ៤ : ភាពមិនច្បាស់លាស់នៃនិរន្តរភាពបរិស្ថាន**

តំបន់កណ្តាលក្រុង ដែលជាតំបន់សណ្ឋាគារមានបញ្ហាជំនន់ភ្ញៀវ សំរាមនៅតាមទីសាធារណៈ និងសំណល់រាវ។ និរន្តរភាពនៃធនធានធម្មជាតិមានលក្ខណៈមិនច្បាស់លាស់ ជាពិសេស ការពឹងផ្អែកយ៉ាងខ្លាំងលើទឹកស្អាតក្រោមដីអាចបង្កលទ្ធភាពគ្រោះថ្នាក់នៃការបាក់ស្រុតដី។ ទាំងនេះគឺជាគ្រោះគំរាមកំហែងដល់និរន្តរភាពទេសចរណ៍។

**បញ្ហាទី ៥ : កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ**

កំណើនយ៉ាងលឿននៃភ្ញៀវទេសចរបានបង្កើតជាបន្ទុកធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលមានស្រាប់។ ភ្ញៀវទេសចរប្រើប្រាស់ និងបញ្ចេញចោលទឹក និងចំនីញផ្សេងៗច្រើនជាងប្រជាជនក្នុងស្រុកធម្មតាយ៉ាងលើសលប់។ ជាពិសេសនៅរដូវដែលមានភ្ញៀវទេសចរច្រើន តំរូវការរបស់ភ្ញៀវទេសចរបានបង្កើតជាសំពាធយ៉ាងខ្លាំងមកលើសមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធក្រុង ដូចជា ការផ្គត់ផ្គង់ទឹក មធ្យោបាយដឹកជញ្ជូន និងអគ្គីសនី។

**បញ្ហាទី ៦ : សមត្ថភាពគ្រប់គ្រងការអភិវឌ្ឍន៍របស់មូលដ្ឋាននៅមានកំរិត**

សមត្ថភាពកំណត់លើការងារអភិវឌ្ឍន៍កើតមាន ដោយសារកង្វះខាតនៃការសំរបសំរួល និងអភិបាលកិច្ចនៅមូលដ្ឋាន។ មូលដ្ឋានហិរញ្ញវត្ថុនៅមូលដ្ឋានមានភាពទន់ខ្សោយ។ ក្រៅពីនេះ មូលដ្ឋានធនធានមនុស្សនៅថ្នាក់ខេត្ត និងស្រុកក៏មានភាពទន់ខ្សោយផងដែរ ជាពិសេស លើការគ្រប់គ្រង និងត្រួតពិនិត្យតាមដានការងារសាធារណការ ការគ្រប់គ្រងដីធ្លី ប្រព័ន្ធព័ត៌មាន និងការគ្រប់គ្រងថវិកា។

## ៣. ចក្ខុវិស័យជាយុទ្ធសាស្ត្រ

### ៣.១ សេណារីយូ

ដោយមានការគិតឃើញថា កំណើនទេសចរណ៍បែបគ្មាននិរន្តរភាពបច្ចុប្បន្ននឹងត្រូវកែប្រែឱ្យទៅជាទេសចរណ៍ ដែលមានគុណភាព និងនិរន្តរភាពច្រើនឡើង សេណារីយូពីរខាងក្រោមត្រូវបានរៀបចំឡើង ដោយយកចិត្តទុកដាក់ជាពិសេសទៅលើទំហំ និងទំរង់ទេសចរណ៍សមស្រប ។ ផ្អែកលើសេណារីយូទាំងពីរ ក្រុមសិក្សាបានព្យាយាមធ្វើការប៉ាន់ស្មានពីចំនួនភ្ញៀវទេសចរ និងចំនួនប្រជាជននៅឆ្នាំ២០១២ និង២០២០ ។

- សេណារីយូ ក : សេណារីយូកំណើនតាមនិន្នាការ
- សេណារីយូ ខ : សេណារីយូកំណើនសមស្រប

ក្រុមសិក្សាបានព្យាយាមធ្វើការប៉ាន់ស្មានត្រួសៗនូវតំរូវការប្រើប្រាស់ទឹក និងអគ្គិសនីរបស់ប្រជាជនមូលដ្ឋាន និងភ្ញៀវទេសចរ និងបន្ទុកបរិស្ថាន ដែលពីតំរូវការទាំងនោះ ដើម្បីវាយតម្លៃពីលទ្ធផលនៃសេណារីយូទាំងពីរដូចមានបង្ហាញក្នុងតារាងខាងក្រោម។

**តារាង ១ : ការប្រៀបធៀបសេណារីយូពីរ**

| សូចនាករ | | ឆ្នាំមូលដ្ឋាន | សេណារីយូ (ក)៖ ការព្យាករណ៍កំណើនតាមនិន្នាការ | | សេណារីយូ (ខ)៖ ការព្យាករណ៍កំណើនសមស្រប | |
|---|---|---|---|---|---|---|
| | | 2004 | 2012 | 2020 | 2012 | 2020 |
| ចំនួនប្រជាជនក្នុងស្រុក (1000 នាក់) | | 139 | 171 | 211 | 171 | 211 |
| ប្រជាជនធ្វើចំណាកស្រុកមកពីក្រៅស្រុកដើម្បីធ្វើការងារ (1000 នាក់) | | 16 | 44 | 100 | 39 | 65 |
| ចំនួនភ្ញៀវទេសចរ (1000 នាក់/ឆ្នាំ) | សរុប | 858 | 2.324 | 4.331 | 2.220 | 2.802 |
| | អន្តរជាតិ | 561 | 1.709 | 3.343 | 1.648 | 2.007 |
| | ក្នុងស្រុក | 297 | 614 | 988 | 572 | 795 |
| តម្រូវការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ | ការប្រើប្រាស់ទឹកនៅរដូវមានភ្ញៀវច្រើន (1000 ម³/ថ្ងៃ) | 9,0 | 20 | 34 | 19 | 28 |
| | តម្រូវការភ្លើងច្រើនបំផុត (MW) | 33 | 72 | 117 | 61 | 74 |
| ផលប៉ះពាល់បរិស្ថាន និងបម្រែបម្រួលអាកាសធាតុ | សំណល់រាវ (BOD: គ.ក្រ/ថ្ងៃ) | 6.364 | 8.199 | 10.663 | 8.172 | 10.141 |
| | ការបូមទឹកក្រោមដីរបស់ឯកជន (1000 ម³/ថ្ងៃ) | 7,0 | 10 | 24 | 9 | 18 |
| | បរិមាណសំណល់រឹង (តោន/ថ្ងៃ) | 99 | 177 | 323 | 176 | 295 |
| | SOX (តោន/ឆ្នាំ) | 35 | 94 | 162 | 77 | 97 |
| ឥទ្ធិពលលើសេដ្ឋកិច្ច មូលដ្ឋាននៃការប្រើប្រាស់ លានដុល្លារ/ឆ្នាំ | | 172 | | 1.023 | | 771 (1.243*) |

* តួលេខនៅក្នុងវង់ក្រចកបញ្ជាក់ពីឥទ្ធិពលលើសេដ្ឋកិច្ចនៃសមាមាត្រភ្ញៀវទេសចរបុគ្គល និងមានកំរិតចំណាយខ្ពស់

**ប្រភព : ក្រុមសិក្សា**

ការប្រៀបធៀបដែលធ្វើការគិតគូរសំខាន់ទៅលើសេដ្ឋកិច្ចជាតិ សេដ្ឋកិច្ចតំបន់ បញ្ហាបរិស្ថាន និងទេសចរណ៍បង្ហាញថា សេណារីយូកំណើនសមរម្យមានលក្ខណៈប្រសើរជាងសេណារីយូកំណើនតាមនិន្នាការ ។

## ៣.៣ ក្រុងសៀមរាប/អង្គរ ឆ្នាំ២០២០

ការបង្កើតឱ្យមានចក្ខុវិស័យមួយគឺជាការចាំបាច់ ដើម្បីលើកទឹកចិត្តគ្រប់ភាគីទាំងអស់ឱ្យគិតពិចារណា និងធ្វើការងាររួមគ្នាយូរអង្វែង ។

ចក្ខុវិស័យមួយសំរាប់ក្រុងសៀមរាប/អង្គរនៅឆ្នាំ២០២០ គឺជា :

*"ក្រុងទេសចរណ៍ដ៏ល្អ និងមានតែមួយគត់ដោយផ្អែកលើ ប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងលក្ខណៈខ្មែរ"។*

ដោយឈរលើទស្សនៈនេះ ក្រុងសៀមរាប/អង្គរនឹងត្រូវមានលក្ខណសម្បត្តិ ដូចតទៅ :

**១. ក្រុងទេសចរណ៍គុណភាពមួយ ដែលភ្ញៀវទេសចរអាចមានអារម្មណ៍ជិតស្និទ្ធទៅនឹងវប្បធម៌ ប្រវត្តិសាស្ត្រ និងសិល្បៈខ្មែរ។**

សៀមរាបនឹងត្រូវកែប្រែឱ្យទៅជាកន្លែងមួយដែលភ្ញៀវទេសចរផ្សេងៗធ្វើការស្នាក់នៅយូរ និងទស្សនាកន្លែងប្រវត្តិសាស្ត្រច្រើនកន្លែងគ្រប់រដូវកាល ។ តាមរយៈការទស្សនាកំសាន្តគ្រប់រដូវកាលនេះ ស្រុកសៀមរាបអាចកាត់បន្ថយកំរិតឡើងចុះខុសគ្នាខ្លាំងនៃចំនួនភ្ញៀវទេសចរនៅតាមរដូវកាល និងធានាឱ្យមាននិរន្តរភាពទេសចរណ៍។ ពេលនោះ សៀមរាបនឹងក្លាយជាមជ្ឈមណ្ឌលសេដ្ឋកិច្ចតំបន់។ នៅក្នុងក្រុងទេសចរណ៍គុណភាព :

- ភ្ញៀវទេសចរបរទេសប្រមាណជាពីរលាននាក់នឹងមកទស្សនាទីនេះ ហើយភ្ញៀវភាគច្រើនស្នាក់នៅច្រើនថ្ងៃជារៀងរាល់ឆ្នាំ
- ភ្ញៀវទេសចរនឹងមិនត្រឹមតែជាភ្ញៀវធ្វើដំណើរកំសាន្តជាក្រុម និងភ្ញៀវដើរកំសាន្តគ្មានផែនការច្បាស់លាស់ប៉ុណ្ណោះទេ ប៉ុន្តែក៏មានភ្ញៀវធ្វើដំណើរជាបុគ្គល ជាគ្រួសារ និងជាភ្ញៀវដែលមានកំរិតចំណាយខ្ពស់ផងដែរ
- ភ្ញៀវដែលស្នាក់នៅច្រើនថ្ងៃប្រហែលអាចមកទស្សនាម្តងទៀតដោយមានបំណងស្វែងយល់បន្ថែមអំពីប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរ
- ភ្ញៀវទេសចរនឹងទទួលអារម្មណ៍រីករាយជាមួយបរិយាកាសក្រុង តាមរយៈការបរិភោគ ការទិញទំនិញ និងការសំរាកកំសាន្ត។ ការនេះនឹងធ្វើឱ្យប្រជាជននៅមូលដ្ឋានច្រើននាក់ទទួលផលប្រយោជន៍សេដ្ឋកិច្ចពីវិស័យទេសចរណ៍។

**២. ក្រុងដែលមានចំនួនមនុស្សសមរម្យ សមស្របទៅនឹងបរិយាកាសអង្គរ**

ក្រុងសៀមរាបគឺជាមូលដ្ឋានរួមសំរាប់ភ្ញៀវទេសចរទស្សនាកំសាន្តរមណីយដ្ឋានអង្គរ។ វាជាក្រុងមានពណ៌បៃតង និងជាក្រុងស្ថិតក្នុងបរិយាកាសអង្គរ។ ក្រុងទាំងមូលត្រូវតែមានសុវត្ថិភាព ស្អាត ងាយស្រួលធ្វើដំណើរ និងមានផាសុកភាព សំរាប់ការស្នាក់នៅរបស់ភ្ញៀវទេសចរ និងការរស់នៅរបស់ប្រជាជនក្នុងស្រុក។ ក្រុងដែលមានប្រជាជនសមស្រប :

- ប្រជាជនចំនួន ២១០.០០០ នាក់នឹងរស់នៅក្នុងក្រុង។ ជាងនេះទៀត ប្រជាជនប្រមាណជា ៦៥.០០០ នាក់មកពីស្រុកផ្សេងៗជុំវិញក្រុងនឹងធ្វើដំណើរចូលក្រុងរៀងរាល់ថ្ងៃ ដើម្បីបំរើការក្នុងវិស័យទេសចរណ៍ និងសកម្មភាពផ្សេងៗ ទៀត ប៉ុន្តែមិនបណ្តាលឱ្យមានការពង្រីកការតាំងទីលំនៅប្រាសចាកពីគំរោងការឡើយ
- សកម្មភាពក្រុងនឹងត្រូវតែមានលក្ខណៈសមស្របទៅនឹងសេវាកម្ម និងទីកន្លែងសាធារណៈ
- តំបន់តាំងទីលំនៅថ្មីត្រូវតែមានទំហំធំបំផុត ពោលគឺ ៤.២៤១ ហិចតា។ តំបន់នោះត្រូវប្រើដើម្បីបញ្ចៀសការចូលទៅរស់នៅក្នុងតំបន់ប្រវត្តិសាស្ត្រ កសិកម្ម ពណ៌បៃតង ឬតំបន់ងាយលិចទឹក និងជំរុញការពង្រីកក្រុងទៅទិសអាគ្នេយ៍

- មជ្ឈមណ្ឌលក្រុងនឹងមានសុវត្ថិភាព ស្អាត និងជាសុខភាព ដើម្បីឱ្យក្លាយជាកន្លែងទេសចរណ៍ដ៏សំខាន់របស់ក្រុង
- ត្រូវរក្សា និងពង្រីកសកម្មភាពកំសាន្ត និងបរិយាកាសរមណីយដ្ឋានអង្គរនៅមុនពេលថ្ងៃលិច និងពេលថ្ងៃលិច សំរាប់ភ្ញៀវទេសចរ និងប្រជាជនមូលដ្ឋាន ពោលគឺកំសាន្តក្នុងព្រៃ និងតាមទិដ្ឋភាពថ្ងៃលិចដ៏អស្ចារ្យ ។

### ៣. ទីក្រុងដែលមានការយកចិត្តទុកដាក់ដល់បរិស្ថាន

ក្រុងគឺជាកន្លែងមានលក្ខណៈសមស្របទៅនឹងបេតិកភណ្ឌ និងលក្ខណៈអង្គរ មានការសន្សំសំចៃទឹក ភ្លើង និងមានការកែច្នៃសំណល់ឡើងវិញ ការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការយល់ដឹងពីបញ្ហាសំណល់ក្នុងចំណោមភ្ញៀវទេសចរ និងប្រជាជន ។ សៀមរាបនឹងក្លាយជាក្រុងគំរូមួយក្នុងប្រទេសកម្ពុជា ។

ពេលនោះ ក្រុងសៀមរាបនឹងមាននិរន្តរភាព ដែលនឹង :

- ឆ្លុះបញ្ចាំងពីគតិបណ្ឌិតសម័យអង្គរលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព វប្បធម៌សម្បូរបែប និងការចូលរួមរបស់ប្រជាជនក្នុងសតវត្សរ៍ទី២១
- ជាប្រភពនៃព្រលឹងសកល ដែលកំពុងត្រូវបានផ្សព្វផ្សាយទៅកាន់តំបន់ផ្សេងៗទៀតនៃសកលលោក
- មានការទាក់ទាញខាងវប្បធម៌ខ្លាំងបំផុតនៅអាស៊ីអាគ្នេយ៍ ។

### ៣.៤ យុទ្ធសាស្ត្រ

រហូតដល់ឆ្នាំ២០២០ យើងស្នើឡើងនូវយុទ្ធសាស្ត្រ៦ ។ យុទ្ធសាស្ត្រទី១ និងទី២គឺជាចលករជំរុញសេដ្ឋកិច្ចស្រុកសៀមរាប ។ យុទ្ធសាស្ត្រទី៣ និងទី៤ត្រូវបានស្នើឡើង ដើម្បីរៀបចំមូលដ្ឋានគ្រឹះមួយសំរាប់ការអភិវឌ្ឍន៍សៀមរាបប្រកបដោយនិរន្តរភាព ។ ដើម្បីធ្វើឱ្យយុទ្ធសាស្ត្រទាំងនេះមានប្រសិទ្ធភាពដូចនេះ សៀមរាបត្រូវពង្រឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងស្ថាប័នតាមរយៈយុទ្ធសាស្ត្រទី៥ និងទី៦ ។

#### យុទ្ធសាស្ត្រទី ១ : លើកកំពស់វិស័យទេសចរណ៍ដោយយកចិត្តទុកដាក់លើភ្ញៀវទេសចរដែលមានការចំណាយខ្ពស់

វិធីសាស្ត្រដ៏ចាំបាច់សំរាប់ក្រុងសៀមរាប/អង្គរឆ្នាំ២០២០ គឺត្រូវបង្កើនឥទ្ធិពលសេដ្ឋកិច្ចវិជ្ជមានរបស់ទេសចរណ៍ទៅលើសេដ្ឋកិច្ចមូលដ្ឋានឱ្យដល់កំរិតអតិបរមា និងត្រូវកំណត់បន្ទុកបរិស្ថានឱ្យនៅក្នុងកំរិតមួយសមស្រប ។ ដោយមានគោលដៅ "ទាក់ទាញភ្ញៀវដែលមានកំរិតចំណាយខ្ពស់" វិធីសាស្ត្រនេះត្រូវផ្សារភ្ជាប់ជាមួយនឹងការបង្កើនបរិមាណនៃការប្រើប្រាស់ផលិតផល និងសេវាកម្មក្នុងស្រុកផ្សេងៗរបស់ភ្ញៀវទេសចរម្នាក់ៗ កាត់បន្ថយចំនួនភ្ញៀវទេសចរនៅរដូវមានភ្ញៀវទេសចរច្រើន និងពង្រីករយៈពេលនៃការស្នាក់នៅរបស់ភ្ញៀវទេសចរទាំងនោះ ។

ដើម្បីទាក់ទាញភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់ ចាំបាច់ត្រូវបំពេញចន្លោះរវាងថាតើក្រុងសៀមរាប/អង្គរអាចផ្តល់អ្វីខ្លះដល់ភ្ញៀវទេសចទាំងនោះ ។ ភ្ញៀវទេសចរដែលមានការចំណាយច្រើនទាំងនោះមិនត្រឹមតែចង់មើលប្រាសាទអង្គរតែមួយប៉ុណ្ណោះទេ តែពួកគេចង់ដឹង និងស្វែងយល់ពីប្រជាជនមូលដ្ឋាន រីករាយនឹងវប្បធម៌ ព្រមទាំងកំសាន្តក្នុងក្រុង ។ ពួកគេមានការយកចិត្តទុកដាក់ខ្លាំងទៅលើបញ្ហាបរិស្ថាន និងមានចិត្តរំភើបរីករាយ ប្រសិនបើការចំណាយទាំងឡាយរបស់គេជួយដល់ការលើកកំពស់ជីវភាពរបស់ប្រជាជនមូលដ្ឋាន និងកិច្ចអភិរក្សវប្បធម៌ខ្មែរ ។

## យុទ្ធសាស្ត្រទី ២ : លើកកំពស់ផលប្រយោជន៍មូលដ្ឋានតាមរយៈទេសចរណ៍ឱ្យដល់កំរិតអតិបរមា

ការកែប្រែទៅរកទេសចរណ៍ដែលមានគុណភាពនឹងមិនត្រឹមតែជួយលើកកំពស់ដល់ឧស្សាហកម្មទេសចរណ៍ប៉ុណ្ណោះទេ តែថែមទាំងជួយដល់សកម្មភាពសេដ្ឋកិច្ចមូលដ្ឋានផ្សេងៗទៀត។ ជាពិសេស ភ្ញៀវទេសចរមកតំសាន្តជាបុគ្គលនាំមកនូវផលប្រយោជន៍សេដ្ឋកិច្ចច្រើនជាងទេសចរជាក្រុម។ យុទ្ធសាស្ត្រមួយដែលអាចនាំឱ្យទៅរកភាពជោគជ័យបាន គឺការផ្សព្វផ្សាយផលិតផលផ្សេងៗក្រោមផ្លាកពាណិជ្ជកម្ម "អង្គរ" - ផ្លាកសញ្ញាអង្គរ ដើម្បីបង្កើតការផ្គត់ផ្គង់ផលិតផលក្នុងស្រុកដល់ទីផ្សារទេសចរណ៍។ អ្នកជំនួញក្នុងស្រុក និងកសិករខិតខំរួមគ្នាឱ្យបានច្រើនថែមទៀតដើម្បីលើកកំពស់ និងពង្រីកផលិតផលរបស់គេសំរាប់ភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់។

## យុទ្ធសាស្ត្រទី ៣ : ធ្វើឱ្យក្រុងឱ្យកាន់តែមានការទាក់ទាញដល់ភ្ញៀវទេសចរ

- ដើម្បីធ្វើឱ្យក្រុងកាន់តែមានភាពទាក់ទាញដល់ភ្ញៀវទេសចរ ការពង្រីកក្រុងគួរតែធ្វើឡើងឱ្យបានត្រឹមត្រូវ ដើម្បីបង្កើតក្រុងទំនើបមួយ។ មិនគួរជំរុញឱ្យមានការសាងសង់សណ្ឋាគារនៅគ្រប់ទីកន្លែងនោះទេ។ តំរូវការសរុបនៃសណ្ឋាគាររហូតដល់ ឆ្នាំ២០២០អាចឆ្លើយតបបាន ដោយការសាងសង់បន្ថែមក្នុងតំបន់សណ្ឋាគារ និងតំបន់វប្បធម៌ និងទេសចរណ៍បច្ចុប្បន្ន។

មជ្ឈមណ្ឌលក្រុងនៅតាមស្ទឹងសៀមរាបគួរតែកែលំអឱ្យដល់កំរិតអតិបរមា សំរាប់ធ្វើជាច្រកយុទ្ធសាស្ត្រមួយ ដើម្បីលើកកំពស់ការទាក់ទាញភ្ញៀវទេសចរក្នុងតំបន់ក្រុងឱ្យមានភាពរស់រវើក។ ដើម្បីសំរេចគោលដៅទាំងនេះ កិច្ចការសំខាន់មួយគឺត្រូវបង្កើតក្របខ័ណ្ឌធ្វើផែនការក្រុងដែលប្រកបដោយភាពប្រាកដប្រជា តម្លាភាព និងស៊ីសង្វាក់គ្នា។

## យុទ្ធសាស្ត្រទី ៤ : ធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន

ដើម្បីបង្កើតក្រុងទេសចរណ៍មួយដែលមានលក្ខណៈប្រកួតប្រជែងអន្តរជាតិ ក្រុងនោះគួរមានភាពស្អាតនៅតាមទីកន្លែងសាធារណៈ ដូចជាផ្លូវថ្នល់ និងស្ទឹង។ ការមានប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ និងការគ្រប់គ្រងសំណល់បានល្អ គឺជាការចាំបាច់។ ក្រុងគួរតែមាននិរន្តរភាពលើមូលដ្ឋានបរិស្ថានធម្មជាតិ ជាពិសេស ធនធានទឹក។ យើងសំណូមពឱ្យមានការកាត់បន្ថយបន្ទុកបរិស្ថានមកនៅត្រឹម ១០ % ក្នុងអំឡុងពេល១៥ ឆ្នាំខាងមុខ តាមរយៈការលើកកំពស់ការយល់ដឹងរបស់ប្រជាជន និងការពង្រឹងច្បាប់ឱ្យបានតឹងរឹងជាងមុន។

សៀមរាបគួរការពារបេតិកភណ្ឌអង្គរផលប៉ះពាល់អវិជ្ជមាន ដែលបណ្តាលមកពីវិស័យទេសចរណ៍ និងការពារបេតិកភណ្ឌទាំងនោះពីលទ្ធភាពបាក់បែកផ្សេងៗ។

## យុទ្ធសាស្ត្រទី ៥ : ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន

ហេដ្ឋារចនាសម្ព័ន្ធគួរតែត្រូវបានពង្រឹងឱ្យដល់កំរិតអតិបរមា សំរាប់បំរើវិស័យទេសចរណ៍ សេដ្ឋកិច្ច និងបរិស្ថាននៅសៀមរាប ដែលជាក្រុងទេសចរណ៍អន្តរជាតិមួយ។ ហេដ្ឋារចនាសម្ព័ន្ធដែលត្រូវតែពង្រឹងជាសំខាន់នោះរួមមាន ការផ្គត់ផ្គង់ទឹក ផ្លូវថ្នល់ ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ ការគ្រប់គ្រងសំណលរឹង និងអគ្គិសនី។

## យុទ្ធសាស្ត្រទី ៦ : ពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន

មូលដ្ឋានសំខាន់ចាំបាច់មួយទៀតដែលជាផ្នែកស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច និងបរិស្ថាន គឺការគ្រប់គ្រង និងហិរញ្ញ-

វត្ថុមូលដ្ឋាន ។ គេគួរតែពន្លឿនគំនិតផ្ដួចផ្ដើមរបស់អភិបាលខេត្តដែលកំពុងតែអនុវត្ត ដើម្បីពង្រឹងការគ្រប់គ្រងការអភិវឌ្ឍន៍ ។

## ៤. យុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់

ដើម្បីធ្វើឱ្យសំរេចនូវចក្ខុវិស័យជាយុទ្ធសាស្ត្រ ឆ្នាំ២០២០ យើងស្នើយុទ្ធសាស្ត្រតំបន់ ដែលជាចំណុចអាទិភាពសំរាប់ការអភិវឌ្ឍន៍ឱ្យបានទូលំទូលាយ ។

### ទស្សនៈលើការបែងចែកតំបន់

សៀមរាបត្រូវបែងចែកជាបីតំបន់ ដូចខាងក្រោម :

- តំបន់ក្រុង
- តំបន់ជនបទ/បេតិកភណ្ឌ
- តំបន់ទន្លេសាប

តំបន់ក្រុងគឺជាតំបន់ទាំងឡាយណាដែលនឹងត្រូវអភិវឌ្ឍឱ្យទៅជាតំបន់ក្រុងនៅត្រឹមឆ្នាំ២០២០ ។ គោលគំនិតអភិវឌ្ឍន៍សំរាប់តំបន់នីមួយៗមានបង្ហាញដូចខាងក្រោម :

**ទស្សនៈអភិវឌ្ឍន៍តំបន់ក្រុង :** ការសិក្សានេះរៀបចំទស្សនៈអភិវឌ្ឍន៍សំរាប់តំបន់ក្រុងឱ្យទៅជា "សៀមរាប : ធ្វើសៀមរាបក្លាយជាក្រុងមានការទាក់ទាញ" ។

**ទស្សនៈអភិវឌ្ឍន៍តំបន់ជនបទ/បេតិកភណ្ឌ :** តំបន់ជនបទ និងតំបន់បេតិកភណ្ឌមានសារៈសំខាន់ដូចគ្នា និងមិនអាចផ្ដាច់ពីគ្នាបានឡើយ ។ ទស្សនៈអភិវឌ្ឍន៍ សំរាប់តំបន់នេះគឺ "តំបន់ជនបទ/បេតិកភណ្ឌ : សហគមន៍ជនបទត្រូវអាចរស់នៅសមស្របជាមួយនឹងបេតិកភណ្ឌ ដែលអាចជួយគាំទ្រដល់ទេសចរណ៍ និងការអភិរក្ស" ។ តាមរយៈទស្សនៈនេះ ត្រូវអនុវត្តយុទ្ធសាស្ត្រពីរដូចខាងក្រោម :

- អភិវឌ្ឍកសិកម្មនៅតំបន់ជាយក្រុងភាគខាងលិច
- លើកកំពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិដោយផ្អែកលើវប្បធម៌ខ្មែរ ។

**ទស្សនៈអភិវឌ្ឍន៍តំបន់បឹងទន្លេសាប :**

តំបន់បឹងទន្លេសាបគឺជាតំបន់មួយដែលមិនអាចខ្វះបាននៅពេលគិតគូរដល់ខេត្តសៀមរាប និងបេតិកភណ្ឌអង្គរ ។ ការសិក្សានេះរៀបចំទស្សនៈអភិវឌ្ឍន៍សំរាប់តំបន់នេះឱ្យទៅជា "បឹងទន្លេសាប : តំបន់ទេសចរណ៍ធម្មជាតិ ដែលមានការការពារ និងប្រើប្រាស់ឱ្យមាននិរន្តរភាពនូវបរិស្ថានធម្មជាតិដ៏សម្បូរបែបដែលផ្ដល់នូវគំនិត ដែលធ្វើឱ្យមានការរីកចំរើនដល់វប្បធម៌ខ្មែរ" ។




រូបទី ១ : ការបែងចែកតំបន់សៀមរាប

# ៥. ផែនការអភិវឌ្ឍន៍តាមវិស័យ

## ៥.១ ផែនការដើម្បីធ្វើសំរេចយុទ្ធសាស្ត្រខាងលើ

យោងតាមយុទ្ធសាស្ត្រខាងលើ គេត្រូវចាត់វិធានការមួយចំនួននៅតាមវិស័យផ្សេងៗ ។ ជំពូកនេះឆ្លុះបញ្ចាំង វិធានការ ដែលត្រូវស្នើឡើងក្នុងផែនការអភិវឌ្ឍន៍តាមវិស័យស្របតាមយុទ្ធសាស្ត្រនីមួយៗ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម ។

**តារាង ២ : យុទ្ធសាស្ត្រ និងផែនការអភិបាលតាមវិស័យ : ខ្លឹមសាររួម**

| ចក្ខុវិស័យជាយុទ្ធសាស្ត្រ | | | ផែនការអភិវឌ្ឍន៍តាមវិស័យ | | |
|---|---|---|---|---|---|
| គោលបំណង | ចក្ខុវិស័យ : ក្រុងសៀមរាប/អង្គរឆ្នាំ ២០២០ | យុទ្ធសាស្ត្រ | សេដ្ឋកិច្ច ការអភិវឌ្ឍន៍ និងបរិស្ថានក្រុង | ហេដ្ឋារចនាសម្ព័ន្ធ | អភិបាល និងហិរញ្ញវត្ថុ |
| ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពដល់ឆ្នាំ ២០២០ តាមរយៈ:<br>• ការលើកកំពស់ទេសចរណ៍តាមវិធីនិរន្តរភាព<br>• លើកកំពស់ និងពង្រីកសេដ្ឋកិច្ចមូលដ្ឋានទាក់ទងនឹងទេសចរណ៍<br>• អភិរក្សបរិស្ថាន<br>• ពង្រឹងសមត្ថភាព | ក្រុងទេសចរណ៍គុណភាព<br>• ក្រុងនៃវប្បធម៌ ប្រវត្តិសាស្ត្រ និង សិល្បៈ<br>• មូលដ្ឋានសំរាប់ទេសចរណ៍រមណីយដ្ឋានអង្គរ<br>• សេវាកម្មប្រកបដោយគុណភាពសំរាប់ការស្នាក់នៅដោយក្តីរីករាយ | ១. លើកកំពស់ទេសចរណ៍ដោយយកចិត្តទុកដាក់ភ្ញៀវដែលមានកំរិតចំណាយខ្ពស់ | អភិវឌ្ឍទេសចរណ៍<br>• អភិវឌ្ឍន៍ និងពង្រីកផ្លូវធ្វើដំណើរឱ្យបានទូលំទូលាយ<br>– តំបន់ឧទ្យានបេតិកភណ្ឌអង្គរ<br>– តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង<br>– តំបន់ជនបទ និងទន្លេសាប<br>– តំបន់រមណីយដ្ឋាននៅឆ្ងាយពីអង្គរ<br>• លើកកំពស់តំលៃវប្បធម៌<br>• កែលំអសេវាកម្ម<br>• ពង្រីកទីផ្សារ និងការផ្សព្វផ្សាយ | មធ្យោបាយដឹកជញ្ជូន<br>• លទ្ធភាពចូលតំបន់បេតិកភណ្ឌ<br>• ការដឹកជញ្ជូនក្នុងឧទ្យានបេតិកភណ្ឌអង្គរ<br>ថាមពល<br>• បំភ្លឺសំរាប់រមណីយដ្ឋានអង្គរ | ការគ្រប់គ្រងការអភិវឌ្ឍន៍<br>• ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់លើកកំពស់ទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ |
| | | ២. ពង្រីកផលប្រយោជន៍មូលដ្ឋានជាអតិបរមាពីទេសចរណ៍ | ការពង្រីកកសិកម្ម និងការផ្គត់ផ្គង់ផលិតផលក្នុងស្រុក<br>• និមិត្តសញ្ញាអង្គរសំរាប់ការផ្គត់ផ្គង់ផលិតផលក្នុងស្រុកឱ្យបានច្រើនឡើង<br>• គិតគូរបញ្ចូលសេដ្ឋកិច្ចមូលដ្ឋានទៅក្នុងវិស័យទេសចរណ៍<br>ការអភិវឌ្ឍន៍ទេសចរណ៍<br>• ទីផ្សារទេសចរណ៍ពេលយប់ | | ការគ្រប់គ្រងការអភិវឌ្ឍន៍<br>• ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់មជ្ឈមណ្ឌលលើកកំពស់ផលិតផលអង្គរ |

| | | | | | |
|---|---|---|---|---|---|
| | **ក្រុងដែលមានមនុស្សសមនឹងបរិយាកាសអង្គរ**<br>• បរិយាកាសអង្គរ<br>• ស្អាត សុវត្ថិភាព ជាសុខភាព និងងាយធ្វើដំណើរកំសាន្ត<br>• ក្រុងមានចំនួនមនុស្សសមស្រប | ៣. ធ្វើឱ្យក្រុងកាន់តែមានការទាក់ទាញដល់ភ្ញៀវទេសចរ | **ការអភិវឌ្ឍន៍ក្រុង**<br>• ការពង្រីកក្រុងតាមគោលដៅដើម្បីបង្កើតជាក្រុងទំនើប<br>• កែលំអមជ្ឈមណ្ឌលក្រុង<br>• អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំរាប់តំបន់ទិសការពង្រីកក្រុង | **មធ្យោបាយដឹកជញ្ជូន**<br>• បណ្តាញផ្លូវសំរាប់តំបន់ការពង្រីកក្រុង<br>• ផ្លូវដើរកំសាន្ត និងសោភ័ណភាពក្រុង<br>• សុវត្ថិភាពក្រុង<br>**ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹកភ្លៀង**<br>• ប្រព័ន្ធបង្ហូរទឹកភ្លៀងសំរាប់តំបន់ការពង្រីកក្រុង<br>**ថាមពល**<br>• ភ្លើងតាមផ្លូវ | **ការគ្រប់គ្រងការអភិវឌ្ឍន៍**<br>• គណៈកម្មការអភិវឌ្ឍន៍សំរាប់ត្រួតពិនិត្យការអភិវឌ្ឍន៍តាមទស្សនៈផែនការក្រុង<br>• ពង្រឹងផែនការប្រើប្រាស់ដី ការចុះបញ្ជីយានយន្ត និងច្បាប់ចរាចរណ៍<br>• ការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់គ្រប់គ្រងព័ត៌មាន |
| | **ក្រុងដែលយកចិត្តទុកដាក់លើ បរិស្ថាន**<br>• សាកសមទៅនឹងបេតិកភណ្ឌ និងលក្ខណៈអង្គរ<br>• សន្សំធនធាន និងថាមពល | ៤. ធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន | **ការគ្រប់គ្រងបរិស្ថាន**<br>• កសាងសមត្ថភាពសំរាប់ការគ្រប់គ្រងបរិស្ថាន<br>• ការលើកកំពស់ការយល់ដឹងបរិស្ថាន<br>• ការផ្តល់ហិរញ្ញវត្ថុសំរាប់ការអភិរក្សបរិស្ថាន<br>• ផែនការអភិវឌ្ឍន៍ដោយយកចិត្តទុកដាក់ដល់បរិស្ថាន | **មធ្យោបាយដឹកជញ្ជូន**<br>• ការដឹកជញ្ជូនដោយមានការគិតគូរពីបរិស្ថានក្នុងឧទ្យានបេតិកភណ្ឌអង្គរ<br>**ធនធានទឹក និងការផ្គត់ផ្គង់ទឹក**<br>• ការគ្រប់គ្រងលើការបូមទឹកក្រោមដី<br>• ការប្រើប្រាស់ទឹកដោយគិតគូរពីបរិស្ថាន<br>**ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់**<br>• ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ<br>**ការគ្រប់គ្រងសំណល់រឹង**<br>• កន្លែងចាក់សំរាមអនាម័យ និងការកាត់បន្ថយសំណល់រឹង<br>**ថាមពល**<br>• ការកាត់បន្ថយម៉ាស៊ីនភ្លើងឯកជន | **ការគ្រប់គ្រងការអភិវឌ្ឍន៍**<br>• គណៈកម្មការសំរាប់វាយតំលៃគំរោងតាមទស្សនៈបរិស្ថាន<br>• ពង្រឹងច្បាប់ និងបទដ្ឋានច្បាប់សំរាប់ការបូមទឹកក្រោមដី និងម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត<br>• ពង្រឹងហិរញ្ញវត្ថុសំរាប់បរិស្ថាន<br>• ភាពជាដៃគូរដ្ឋ-ឯកជនដើម្បីគ្រប់គ្រងសំណល់រឹង<br>• ការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់គ្រប់គ្រងព័ត៌មាន<br>**ការផ្តល់សិទ្ធិអំណាចដល់សហគមន៍**<br>• ការរស់នៅរបស់ប្រជាជនជាមួយនឹងបេតិកដ្ឋានអង្គរ |

| | | | | | |
|---|---|---|---|---|---|
| | *ក្រុងដ៏ល្អនិងមានជំហរមួយ ដោយផ្អែក លើប្រវត្តិសាស្ត្រ សិល្បៈ និងលក្ខណៈខ្មែរ*<br>• *បង្ហាញពីគំនិតប្រឌិតសម័យអង្គរដើម្បីជាគំរូនៅសតវត្សរ៍ទី ២១សំរាប់ការអភិវឌ្ឍន៍ ប្រកបដោយនិរន្តរភាព និងភាពសម្បូរបែបខាង វប្បធម៌*<br>• *ការទាក់ទាញដោយសារ វប្បធម៌នៅអាស៊ីអាគ្នេយ៍* | ៥.<br>ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ សំរាប់ភ្ញៀវទេសចរណ៍ និងប្រជាជន | | **<u>មធ្យោបាយដឹកជញ្ជូន</u>**<br>• បណ្តាញផ្លូវគ្រប់គ្រាន់សំរាប់ភ្ញៀវ និងប្រជាជន<br>**<u>ធនធានទឹក និងការផ្គត់ផ្គង់ទឹក</u>**<br>• ការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព និងការផ្គត់ផ្គង់ទឹក<br>**<u>ការគ្រប់គ្រងសំណល់រឹង</u>**<br>• ការធ្វើឱ្យក្រុងគួរជាទីស្រលាញ់<br>**<u>ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ</u>**<br>• ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹកភ្លៀងប្រកបដោយនិរន្តរភាពដើម្បីអនាម័យ និងសោភ័ណភាពក្រុង<br>**<u>ថាមពល</u>**<br>• ថាមពលដែលអាចទុកចិត្តបានដោយបង្កបន្ទុកបរិស្ថានតិចតួច | **<u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u>**<br>• ការធ្វើផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យគំរោង<br>**<u>ការផ្តល់ហិរញ្ញវត្ថុដល់មូលដ្ឋាន</u>**<br>• មូលនិធិអភិវឌ្ឍន៍សៀមរាប |
| | | ៦.<br>ពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន | | | **<u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u>**<br>• ធ្វើឱ្យរលូននូវរដ្ឋបាលមូលដ្ឋានដោយមានតម្លាភាព និងការទទួលខុសត្រូវ<br>• ភាពជាដៃគូថ្មីរវាងផ្នែកឯកជន ប្រជាជន និងរដ្ឋាភិបាល<br>• ពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ផ្សេងៗ<br>• អភិវឌ្ឍន៍ធនធានមនុស្សសំរាប់ការអភិវឌ្ឍន៍<br>**<u>ការផ្តល់ហិរញ្ញវត្ថុដល់មូលដ្ឋាន</u>**<br>• ពង្រឹងមូលដ្ឋានហិរញ្ញវត្ថុសំរាប់មូលដ្ឋាន<br>**<u>ការផ្តល់សិទ្ធិអំណាចដល់សហគមន៍</u>**<br>• ពង្រឹងសមត្ថភាពប្រជាជន |

## ៥.២ ផែនការអភិវឌ្ឍន៍តាមវិស័យ

ផែនការអភិវឌ្ឍន៍តាមវិស័យត្រូវបានស្នើឡើង ដូចមានបង្ហាញក្នុងតារាងខាងក្រោម ។

**តារាង ៣ : ផែនការអភិវឌ្ឍន៍តាមវិស័យ**

| វិស័យ | គោលបំណង | យុទ្ធសាស្ត្រ | គំរោង/កម្មវិធី |
|---|---|---|---|
| អភិវឌ្ឍន៍ក្រុង | ធ្វើឱ្យក្រុងកាន់តែមានការទាក់ទាញ | ១. បង្កើតក្រុងទំនើបដោយមានការអនុវត្តន៍ផែនការក្រុងប្រកបដោយប្រសិទ្ធភាពខ្ពស់<br>២. អភិវឌ្ឍឡើងវិញនូវតំបន់ផ្សារចាស់ និងធ្វើសមាហរណកម្មតំបន់នេះ<br>៣. អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវក្នុងក្រុង | U-1 លើកកំពស់តំបន់មណ្ឌលក្រុង<br>U-2 កសាងសមត្ថភាពធ្វើផែនការក្រុង<br>U-3 បង្កើតបញ្ជីសារពើភ័ណ្ឌនៃស្ថាបត្យកម្មប្រវត្តិសាស្ត្រ<br>U- 4 អភិវឌ្ឍតំបន់តាំងទីលំនៅ<br>U-5 ធ្វើផែនការ និងអនុវត្តតំបន់វប្បធម៌ និងទេសចរណ៍ |
| ការគ្រប់គ្រងបរិស្ថាន | ការធ្វើសៀមរាបមានសោភ័ណភាព និងនិរន្តរភាពខាងបរិស្ថាន | ១. ពង្រឹងសមត្ថភាពស្ថាប័នលើការគ្រប់គ្រងបរិស្ថានដើម្បីដោះស្រាយបញ្ហាដែលបណ្ដាល មកពីការ អភិវឌ្ឍន៍យ៉ាងលឿន<br>២. ផែនការអភិវឌ្ឍន៍ដែលគិតគូពីបញ្ហាប.ស្ថ<br>៣. ជំរុញឱ្យមានការកែប្រែអាកប្បកិរិយាមនុស្ស អោយចេះស្រលាញ់បរិស្ថាន<br>៤. បង្កើតប្រព័ន្ធហិរញ្ញវត្ថុសំរាប់ការអភិរក្សបរិស្ថាន | E-1 ពង្រឹងសមត្ថភាពស្ថាប័ន<br>E-2 លើកកំពស់ការយល់ដឹងបរិស្ថាន<br>E-3 ប្រព័ន្ធប្រមូលកំរៃរួមនៃសេវាកម្មសាធារណៈ |
| ការអភិវឌ្ឍន៍ទេសចរណ៍ | បង្កើតតំបន់ទេសចរណ៍គុណភាពមួយដោយផ្អែកលើបរិបទនៃប្រវត្តិ-សាស្ត្រ និងវប្បធម៌អង្គរ | ១. អភិវឌ្ឍតំបន់ទេសចរណ៍ និងផ្លូវទស្សនាកំសាន្ត ឱ្យបានច្រើន<br>២. ផ្តល់ឱ្យភ្ញៀវទេសចរនូវរសជាតិវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងធម្មជាតិរបស់ខ្មែរ | TO-1 គំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបណ្ដាញទេសចរណ៍បេតិកភណ្ឌអង្គរ<br>TO-2 គំរោងអភិវឌ្ឍន៍ទីផ្សារសំរាប់ពេលយប់<br>TO-3 កម្មវិធីលើកកំពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរដ្ឋ-ឯកជន<br>TO-4 ការអភិវឌ្ឍន៍ និងការលើកកំពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ<br>TO-5 ពង្រឹងការបណ្តុះបណ្តាលលើជំនាញនាំភ្ញៀវ និងការបង្កើតប្រព័ន្ធនាំភ្ញៀវទំនើប<br>TO-6 សិក្សាលំអិតលើលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋាន ។ |
| ៥. ការពង្រីកកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក | បង្កើតផ្លាកសញ្ញាអង្គរសំរាប់ពង្រីកការផ្គត់ផ្គង់ផលិតផលក្នុងស្រុកដើម្បីលើកកំពស់ផលប្រយោជន៍សេដ្ឋកិច្ចក្នុងស្រុក | ១. បង្កើតប្រព័ន្ធគាំទ្រ<br>២. យកចិត្តទុកដាក់ទីផ្សារទេសចរណ៍ព្រមទាំង ទីផ្សារថ្នាក់កណ្ដាលដែលកំពុងមានកំណើន<br>៣. ពង្រឹងទំនាក់ទំនងរវាងទេសចរណ៍ និងសេដ្ឋកិច្ចមូលដ្ឋាន<br>៤. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់លើកកំពស់ផលិតផលក្នុងស្រុក | A-1 ការអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ (APPC)<br>A-2 ចលនាភូមិមួយ ផលិតផលមួយ<br>A-3 ការអភិវឌ្ឍន៍ភូមផលិតកម្ម<br>A-4 ការតាំងពិព័រណ៍ផលិតផលអង្គរ |

| | | | |
|---|---|---|---|
| ៦. មធ្យោបាយដឹកជញ្ជូន | ១. ផ្តល់បណ្តាញផ្លូវ និងមុខងារគ្រប់គ្រាន់សំរាប់ភាពងាយស្រួលដល់ការធ្វើដំណើរ<br>២. ធ្វើឱ្យភ្ញៀវទេសចរពេញចិត្ត នឹងទស្សនាបេតិកភណ្ឌអង្គរ និងស្នាក់នៅសៀមរាប | ១.កែលំអស្ថានភាពរាំងស្ទះ និងបង្កើតបណ្តាញផ្លូវរណបប្រទាក់ក្រឡាក្នុងតំបន់ក្រុង<br>២.កែលំអស្ថានភាពផ្លូវ និងស្ពានក្នុងតំបន់ក្រុង<br>៣. បង្កើតបណ្តាញផ្លូវសំរាប់តំបន់ពង្រីកក្រុងនៅពេលអនាគត<br>៤.លើកកំពស់លទ្ធភាពធ្វើដំណើរទៅរមណីយដ្ឋានអង្គរផ្សេងៗ<br>៥.បង្កើតប្រព័ន្ធថែទាំផ្លូវឱ្យបានទូលំទូលាយ និង មានប្រសិទ្ធភាព | T-1 គំរោងកែលំអស្ពានពីសម័យបារាំង<br>T-2 គំរោងសាងសង់ផ្លូវរណបប្រទាក់ក្រឡាស្របនឹងផ្លូវជាតិលេខ៦ ( ជំហាន ១)<br>T-3 កែលំអផ្លូវសន្តិភាពហ៊ុន សែន ( ជំហាន ២)<br>T-4 *សាងសង់បញ្ចប់បណ្តាញផ្លូវរណបក្នុងតំបន់ក្រុងរហូតដល់ឆ្នាំ២០១២( ជំហាន ៣)*<br>T-5 សាងសង់បញ្ចប់បណ្តាញផ្លូវរណបប្រទាក់ក្រឡាក្នុងតំបន់ក្រុងរហូតដល់ឆ្នាំ២០២០ ( ជំ ៤)<br>T-6 ការលើកកំពស់ស្ថាប័ន និងយុទ្ធនាការសំរាប់សុវត្ថិភាពតាមផ្លូវថ្នល់<br>T-7 គំរោងស្តារបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌឆ្ងាយៗ<br>T-8 ចាប់ផ្តើមការដឹកជញ្ជូនសាធារណៈដែលមិនបំពុល បរិស្ថាក្នុងរមណីយដ្ឋានអង្គរ<br>T-9 គំរោងសាងសង់ផ្លូវសំរាប់ជិះកង់ក្នុងរមណីយដ្ឋានអង្គរ<br>T-10 ការលើកកំពស់ស្ថាប័នស.រថែទាំផ្លូវឱ្យមានប្រសិទ្ធភាព |
| ៧. ធនធានទឹក និងការផ្គត់ផ្គង់ទឹក | ១. អភិវឌ្ឍធនធានទឹកសំរាប់ការផ្គត់ផ្គង់ទឹក កសិកម្ម និងបរិស្ថាន<br>២. លើកកំពស់សមត្ថភាព និងអត្រាគ្របដណ្តប់នៃសេវាម្ផគត់ផ្គង់ទឹកសាធារណៈ<br>៣. គ្រប់គ្រង និងអភិរក្សទឹកក្រោមដី | **<u>ការអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានទឹក</u>**<br>១.អភិវឌ្ឍធនធានទឹកគ្រប់ដោយនិរន្តរភាព<br>២.ផែនការអភិវឌ្ឍធនធានទឹកដែលមានប្រសិទ្ធភាពខ្ពស់<br>៣. លើកកំពស់អនាម័យនៅតាមស្ទឹង និង បរិស្ថានទឹកនៃរមណីយដ្ឋានអង្គរ<br>**<u>ការផ្គត់ផ្គង់ទឹក</u>**<br>១.ផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់សំរាប់ប្រជាជន និងជំនួញ<br>២.គ្រប់គ្រងការផ្គត់ផ្គងទឹកឱ្យមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយគំលាតរវាងរយៈពេលត្រូវការទាប និងរយៈពេលត្រូវការខ្ពស់<br>៣. លើកកំពស់សេវាកម្មផ្គត់ផ្គង់ទឹកដើម្បីពង្រីកអត្រាគ្របដណ្តប់តាមរយៈការខិតខំប្រឹងប្រែងបំពេញចិត្តអតិថិជន ។ | W-1 ការតំណត់នៅថ្នាក់ខេត្តលើការចុះបញ្ជីនៃអណ្តូងពាណិជ្ជកម្ម<br>W-2 អនុក្រឹត្យស្តីពីទឹកក្រោមដី<br>W-3 ការជំនួសបំពង់ទឹកចាស់ៗ<br>W-4 សិក្សាបែបយុទ្ធសាស្ត្រអំពីការគ្រប់គ្រងធនធានទឹករួមគ្នាសំរាប់អាងស្ទឹងសៀមរាប និងស្ទឹងរលួស<br>W-5 អភិវឌ្ឍ ប្រព័ន្ធផ្គត់ផ្គង់ទឹកក្នុង ក្រុងសៀមរាប ( ជំហាន១)<br>W-6 អភិវឌ្ឍធនធានទឹកនៅបារាយណ៍ភាគឦសាន<br>W-7 អភិវឌ្ឍ ប្រព័ន្ធផ្គត់ផ្គង់ទឹកនៅ ក្រុងសៀមរាប ( ជំហានទី ២) |
| ៨. ការគ្រប់គ្រងសំណល់រឹង | ធ្វើឱ្យក្រុងគួរឱ្យស្រលាញ់ | ១. ពង្រឹងការយល់ដឹងបរិស្ថានរបស់ប្រជាជន<br>២. បង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានបច្ចេកទេសខ្ពស់<br>៣. បង្កើតប្រព័ន្ធហិរញ្ញវត្ថុសមស្រប<br>៤. ពង្រឹងភាពជាដៃគូរដ្ឋ-ឯកជន | SW-1 ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសំណល់រឹង<br>SW-2 ការពង្រឹងប្រព័ន្ធប្រមូលសំណល់<br>SW-3 ការអភិវឌ្ឍន៍កន្លែងចាក់សំរាមអនាម័យ |

| | | | |
|---|---|---|---|
| ៩. ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ | បង្កើតប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវប្រកបដោយនិរន្តរភាពសំរាប់ក្រុងដែលមានអនាម័យ និងសោភ័ណភាព | ១. រៀបចំឱ្យមានការគ្រប់គ្រងសំណល់រួម<br>២. គ្រប់គ្រងទឹកភ្លៀង<br>៣. ការគ្រប់គ្រងសំណល់រាវ | SD-1 គំរោងអភិវឌ្ឍន៍ទេសចរណ៍ទន្លេមេគង្គភាគ A1: ការលើកកំពស់ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងតំបន់១ ស្ថិតនៅភាគខាងលិចស្រុក<br>SD-2 គំរោងអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរ : ប្រព័ន្ធបង្ហូរទឹកនៅភាគខាងកើតស្រុក<br>SD-3 គំរោងប្រព័ន្ធបង្ហូរសំណល់រាវនៅសៀមរាប-ជំហាន១: ប្រព័ន្ធបង្ហូរទឹក និងសំណល់តំបន់១ ស្ថិតនៅភាគខាងលិចស្រុក<br>SD-4 គំរោងប្រព័ន្ធបង្ហូរសំណល់រាវនៅសៀមរាប-ជំហាន២: ប្រព័ន្ធបង្ហូរសំណល់នៅតំបន់មួយស្ថិតនៅភាគខាងកើត<br>SD-5 គំរោងបញ្ចេញទឹកភ្លៀងមណ្ឌលក្រុងសៀមរាប: ប្រព័ន្ធបង្ហូរសំណល់រាវនៅភាគខាងលិចស្រុក<br>SD-6 គំរោងគ្រប់គ្រងទឹកស្អុយនៅសៀមរាប ជំហាន ១ : ការចោលសំណល់កកពីសំណល់រាវនៅខាងលិចស្រុក<br>SD-7 គំរោងគ្រប់គ្រងទឹកស្អុយនៅសៀមរាប ជំហាន ២ : ការចោលសំណល់កក់ខាងកើតស្រុក<br>SD-8 គំរោងបញ្ចេញចោលទឹកបន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្ម ជំហាន ១ : ការបញ្ចេញចោលសំណល់រាវក្រោយពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្មនៅតំបន់ ២ ភាគខាងលិចស្រុក<br>SD-9 គំរោងបញ្ចេញចោលទឹកបន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្ម ក្នុងអាងប្រព្រឹត្តិកម្ម ជំហាន១ : ការបញ្ចេញចោលសំណល់រាវក្រោយពីឆ្លងកាត់ ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្មនៅតំបន់ ២ ភាគខាងកើតស្រុក ។ |
| ១០. ថាមពល | ផ្គត់ផ្គង់ថាមពលដែលគួរឱ្យទុកចិត្តសំរាប់ទាំងអស់គ្នាដោយមានបន្ទុកបរិស្ថានតិច | ១. លើកកំពស់ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធអគ្គីសនី<br>១.១ ប្រភពថាមពលបន្ថែម<br>១.២ ពង្រីក និងកែលំអបណ្តាញអគ្គីសនី<br>២. អនុវត្តច្បាប់ EdC<br>២.១ ពិនិត្យអត្រាពន្ធ និងតំលៃភ្ជាប់<br>២.២ ពង្រឹង EdC<br>៣. គ្រប់គ្រងដោយផ្អែកលើច្បាប់ បទបញ្ជា និងក្រឹត្យច្បាប់ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន | PO-1 ការបំពាក់ជាបន្ទាន់នូវម៉ាស៊ីនប្រើម៉ាស៊ូត<br>PO-2 គំរោងពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតនៅពេលបច្ចុប្បន្ន<br>PO-3 គំរោងសំរាប់ពង្រីកបណ្តាញបែងចែកអគ្គីសនី<br>PO-4 គំរោងសំរាប់តម្លើង និងជួសជុលភ្លើងតាមវិថី<br>PO-5 ការធ្វើផែនការនៃការប្រើប្រាស់អគ្គីសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់ប្រាសាទអង្គរវត្ត និងប្រាសាទផ្សេងៗទៀត ។<br>PO-6 ការធ្វើផែនការសំរាប់បំភ្លឺតំបន់ដែលគ្មានភ្លើង<br>PO-7 ជំនួយដល់ការកសាងសមត្ថភាព EdC<br>PO-8 ជំនួយលើការពិនិត្យឡើងវិញនូវអត្រាពន្ធភ្លើង<br>PO-9 គំរោងសំរាប់ពិនិត្យ ឬបង្កើតច្បាប់ |

| | | | |
|---|---|---|---|
| ១១. ការគ្រប់គ្រងការអភិវឌ្ឍន៍ | បង្កើតរដ្ឋបាលស្វយ័ត និងឯកភាពនៅមូលដ្ឋានសំរាប់សៀមរាបដើម្បីធានាតម្លាភាព និងគណនេយ្យភាព | ១. រដ្ឋបាលស្វយ័ត និងឯកភាព<br>២. ពង្រឹងអាជ្ញាធរខេត្ត<br>៣. ធានាឱ្យមានថវិកាគ្រប់គ្រាន់<br>៤. បង្កើតសភាមូលដ្ឋានសំរាប់តម្លាភាព និងគណនេយ្យភាព<br>៥. បង្កើតក្របខ័ណ្ឌច្បាប់ | L-1 គណៈកម្មការអភិវឌ្ឍន៍<br>L-2 កែទំរង់រចនាសម្ព័ន្ធគ្រប់គ្រង<br>L-3 អភិវឌ្ឍធនធានមនុស្សសំរាប់មន្ត្រីរដ្ឋាភិបាលនៅថ្នាក់ខេត្ត<br>L-4 អភិវឌ្ឍ និងអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់<br>L-5 កែទំរង់ថវិកាមូលដ្ឋានសំរាប់រដ្ឋបាលឯកភាព |
| ១២. ផ្តល់ហិរញ្ញវត្ថុមូលដ្ឋាន | ផ្តល់ធនធានហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមក្នុងខេត្តសៀមរាបប្រកបដោយនិរន្តរភាព | ១. បង្កើនធនធានហិរញ្ញវត្ថុរបស់អាជ្ញាធរខេត្ត<br>២. *កែលំអការធ្វើផែនការថវិកា/ការអនុវត្តន៍* និងធនធានមនុស្ស<br>៣. លើកកំពស់តម្លាភាព<br>៤. បង្កើតវេទិកាសំរាប់តម្លាភាពថវិកា | |
| ១៣. ការផ្តល់សិទ្ធិអំណាចដល់សហគមន៍ | ពង្រឹងសមត្ថភាពជួយខ្លួនឯងរបស់ប្រជាជនដើម្បីចូលរួម និងសំរបសំរួលជាមួយនឹងរដ្ឋាភិបាល | ១. ពង្រឹងសមត្ថភាពអាជ្ញាធរខេត្តសំរាប់ធ្វើការងារសំរួលជាមួយប្រជាជន<br>២. ជំរុញប្រជាជន និងផ្អែកឯកជនឱ្យចូលរួមក្នុងការអភិវឌ្ឍន៍នៅកំរិតសហគមន៍<br>៣. បង្កើតកម្មវិធីនៅតាមសហគមន៍តាមរយៈភាពជាដៃគូរដ្ឋ-ប្រជាជន | C-1 រៀបចំផែនទីប្រើប្រាស់ដីធ្លី<br>C-2 ការធ្វើផែនការសហគមន៍<br>C-3 បង្កើតសមាគមដោយផ្អែកលើគំរោង<br>C- 4 ការអនុវត្តន៍របស់សហគមី<br>C-5 ការសិក្សាច្បាប់លំអិតអំពីតំបន់ដែលប្រជាជន និងបេតិកភណ្ឌដែលអាចមានជីវិតរស់នៅជាមួយគ្នាបាន<br>C-6 ផែនការគ្រប់គ្រងអង្គរ និងការអភិវឌ្ឍន៍ស.ត<br>C-7 ចងក្រងពីសេចក្តីត្រូវការរបស់ប្រជាជន |

## ៦. គំរោង និងកម្មវិធី

ក្រុមសិក្សាស្នើគំរោង និងកម្មវិធីចំនួន៦៥។ ក្នុងចំណោមគំរោងទាំង ៦៥ នេះ ក្រុមសិក្សាបានធ្វើការជ្រើសរើសគំរោង និងកម្មវិធីអាទិភាពចំនួន១៣ ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យពីរដូចខាងក្រោម :

### ១. *សារៈសំខាន់រយៈពេលខ្លី*

គំរោងមួយអាចមានអាទិភាពរយៈពេលខ្លី ដោយសារគំរោងនោះមានភាពចាំបាច់ ហើយអាចអនុវត្តមានប្រសិទ្ធភាពរយៈពេលខ្លី។

### ២. *សារៈសំខាន់រយៈពេលវែង*

គំរោងមួយមានអាទិភាពរយៈពេលវែង ដោយសារគំរោងនោះ :

- ឆ្លុះបញ្ចាំងផ្ទាល់ពីគោលគំនិតនៃផែនការមេ
- ជាការចាំបាច់ ដើម្បីនាំទៅរកភាពជោគជ័យនៃផែនការមេក្នុងរយៈពេលយូរ និង
- ត្រូវការអនុវត្តន៍មុន បើពិនិត្យទៅលើរយៈពេលរៀបចំដ៏យូរ។

## តារាង ៤ : គំរោង និងកម្មវិធី (១/២)

| ល.រ | យុទ្ធសាស្ត្រពាក់ព័ន្ធ | វិស័យ | លេខកូដ | ឈ្មោះគំរោង/កម្មវិធី | ការអធិប្បាយសង្ខេប | ស្ថាប័ន/ទីភ្នាក់ងារអនុវត្ត | អាទិភាព | តម្លៃ ១០០០$ | ឆ្នាំអនុវត្ត 2006 | 2012 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 3,4,5 | ក្រុង | U-1 | ការកែលំអតំបន់មណ្ឌលក្រុង | ហេដ្ឋារចនាសម្ព័ន្ធ និងទេសភាពទាំងផ្សេងៗ | ខេត្ត មន្ទីរពាក់ព័ន្ធ | អាទិភាព | 7.600 | | | |
| 2 | 3,5,6 | | U-2 | កសាងសមត្ថភាពធ្វើផែនការក្រុង | អភិវឌ្ឍសមត្ថភាពសំរាប់ចក្ខុវិស័យ និងផែនការប្រើប្រាស់ដី ធ្វើផែនការក្រុង និងផែនការប្រើប្រាស់ដី | ដែនដី ស្រុក អប្សរា ខេត្ត | អាទិភាព | 500 | | | |
| 3 | 3 | | U-3 | ការចុះបញ្ជីស្ថាប័ត្យកម្មប្រវត្តិសាស្ត្រ | បញ្ជីសារពើភ័ណ្ឌស្ថាបត្យកម្មពីសម័យបារាំង | អប្សរា /ខេត្ត | | 200 | | | |
| 4 | 3,5 | | U-4 | លើកកំពស់ការអ.វតំបន់លំនៅដ្ឋាន | ផ្តល់បរិយាកាសរស់នៅល្អសំរាប់ជំណួលថ្មី | អប្សរា ស្រុក ឯកជន | | n/a | | | |
| 5 | 1,3,4 5 | | U-5 | អភិវឌ្ឍតំបន់វប្បធម៌ និងទេសចរណ៍ | អ.វតំបន់សំរាប់ការទ/ទ និងសណ្ឋាគារប្រណិត | អប្សរា វិនិយោគិនឯកជន | | n/a | | | |
| 6 | 4,6 | បរិស្ថាន | E-1 | អភិវឌ្ឍសមត្ថភាពស្ថាប័ន | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់វិស័យសាធារណៈ | ខេត្ត សាធារណការ ម.បរិស្ថាន ប្រជាជន | | 310 | | | |
| 7 | 3,4 | | E-2 | លើកកំពស់ការយល់ដឹងបរិស្ថាន | យុទ្ធនាការបរិស្ថាន ជាពិសេស ចំពោះសិស្សសាលា | សាលាបឋមសិក្សា | អាទិភាព | 330 | | | |
| 8 | 4,5,6 | | E-3 | ប្រមូលតំរូវលើសេវាកម្មសាធារណៈ | ប្រមូលថ្លៃមគ្គសំរាប់ថ្លៃទឹក សំណល់រាវ និងសំណល់រឹង | [illegible] | | 310 | | | |
| 9 | 1,2,3, 5,6 | ទេសចរណ៍ | TO-1 | បណ្តាញទេសចរណ៍បេតិកភណ្ឌខ្មែរ និងការអភិវឌ្ឍន៍ | លើកកំពស់កន្លែងទេសចរណ៍ថ្មីនៅជុំវិញសៀមរាប | ក្រ. និងម.ទេសចរណ៍ អប្សរា សាធារណការ ក្រ.វប្បធម៌ | អាទិភាព | 26.550 | | | |
| 10 | 2,3 | | TO-2 | អភិវឌ្ឍទីផ្សារពេលយប់ | បង្កើតការទាក់ទាញ និងជំរើសសំរាប់កំសាន្តពេលយប់ | វិស័យឯកជន | | 260 | | | |
| 11 | 1,2,3 | | TO-3 | លើកកំពស់គុណភាពទេសចរណ៍តាមរយៈភ្ញៀ-ឯកជន | ភាពជាដៃគូរដ្ឋ- ឯកជនសំរាប់ទីផ្សារ និងការផ្សព្វផ្សាយ | នឹងកំណត់នៅពេលក្រោយ | អាទិភាព | n/a | | | |
| 12 | 1,2,6 | | TO-4 | អភិវឌ្ឍ និងលើកកំពស់ទេសចរណ៍ធម្មជាតិ និងតាមភូមិ | អង្កេតតាមភូមិ អង្កេតសំរាប់គំរោងសាកល្បង និងជ្រើសរើសផលិតផលសំរាប់ទេសចរ | អង្គការមិនមែនរដ្ឋាភិបាល អប្សរា | | 158 | | | |
| 13 | 1,2 | | TO-5 | បណ្តុះបណ្តាលជំនាញនាំភ្ញៀវ និងប្រព័ន្ធនាំភ្ញៀវថ្មី | ពង្រឹងកម្មវិធីបណ្តុះបណ្តាលនាំភ្ញៀវ និងលើកកំពស់ប្រព័ន្ធផ្តល់លិខិតអនុញ្ញាត | ក្រ. និងមន្ទីរទេសចរណ៍ អប្សរា | | 211 | | | |
| 14 | 1,5 | | TO-6 | សិក្សាពីសមត្ថភាពទទួលភ្ញៀវតាមទីកន្លែង និងការគ្រប់គ្រង | សិក្សា/វិភាគលំហូរភ្ញៀវ សមត្ថភាពទីកន្លែង និងការគ្រប់គ្រងទីកន្លែង | អប្សរា | | 163 | | | |
| 15 | 1,2,6 | កសិកម្ម និងជនបទ | A-1 | ការអភិវឌ្ឍធនធានមនុស្ស និងមជ្ឈ. មណ្ឌលផ្សព្វផ្សាយផលិតផល | អភិវឌ្ឍសមត្ថភាពខេត្ត និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលក្នុងស្រុក | ខេត្ត APPC | អាទិភាព | 80 | | | |
| 16 | 1,2,6 | | A-2 | ចលនាភូមិមួយផលិតផលមួយ | លើកកំពស់ចលនាភូមិមួយ ផលិតផលមួយ | ខេត្ត APPC | | 60 | | | |
| 17 | 1,2,6 | | A-3 | អភិវឌ្ឍភូមិផលិតកម្ម | សកម្មភាពប្រមូលផ្តុំរបស់អ្នកភូមិ និងការទំនាក់ទំនងជាមួយទេសចរណ៍ | ខេត្ត APPC | | 36 | | | |
| 18 | 1,2,3 | | A-4 | ការតាំងពិព័រផលិតផលអង្ករ | រៀបចំការតាំងពិព័រផលិតផលអង្ករ ស្របជាមួយគ្នានៅនឹងគំរោងសាកល្បង | APPC | | 108 | | | |
| 19 | 3,5 | ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន | TR-1 | កែលំអស្ពានសល់ពីសម័យបារាំង | សាងសង់ស្ពានបន្ថែមក្នុងស្ទឹងសៀមរាប | មន្ទីរសាធារណការ | អាទិភាព | 957 | | | |
| 20 | 3,5 | | TR-2 | បណ្តាញផ្លូវល្បឿន ដំណាក់ ១ | អភិវឌ្ឍផ្លូវបីនៅក្នុងតំបន់ក្រុង | សាធារណការ និងខេត្ត | អាទិភាព | 10.839 | | | |
| 21 | 3,5 | | TR-3 | បណ្តាញផ្លូវល្បឿន ដំណាក់ ២ | សាងសង់បញ្ចប់ផ្លូវហ៊ុន សែន | មន្ទីរសាធារណការ | | 6.817 | | | |
| 22 | 3,5 | | TR-4 | បណ្តាញផ្លូវល្បឿន ដំណាក់ ៣ | បង្កើតផ្លូវជុំខាងក្នុង | សាធារណការ និងខេត្ត | | 16.736 | | | |
| 23 | 3,5 | | TR-5 | បណ្តាញផ្លូវល្បឿន ដំណាក់ ៤ | អភិវឌ្ឍផ្លូវធំៗក្នុងតំបន់ពាក់កណ្តាលទីប្រជុំជនបច្ចុប្បន្ន | ខេត្ត | | 14.921 | | | |
| 24 | 3,6 | | TR-6 | អភិវឌ្ឍផ្លូវធំៗ នៅតាមតំបន់ពាក់កណ្តាលក្រុងបច្ចុប្បន្ន | ពង្រឹងច្បាប់ចរាចរលើផ្នែកការផ្តល់សិទ្ធិបើកបរ សុវត្ថិភាព និងការពាក់មួកការពារ | ប៉ូលិស សាធារណការ និងខេត្ត | | 7.000 | | | |
| 25 | 2,3,5 | | TR-7 | ស្តារបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌនៅជនបទ | កែលំអផ្លូវទៅកាន់រមណីយដ្ឋានប្រាសាទឆ្ងាយៗ | សាធារណការ និង អភិវឌ្ឍន៍ជនបទ | អាទិភាព | 33.150 | | | |
| 26 | 3,4,5 | | TR-8 | មធ្យោបាយដឹកជញ្ជូនសាធារណៈ ដែលមិនបំពុលបរិស្ថាន | ប្រព័ន្ធឡានក្រុងដែលមានការបំពុលតិចទៅកាន់រមណីយដ្ឋានប្រាសាទបុរាណ | អប្សរា | | 7.104 | | | |
| 27 | 3,4,5 | | TR-9 | សាងសង់ផ្លូវសំរាប់ជិះកង់ | បង្កើតផ្លូវសំរាប់កង់នៅតាមរមណីយដ្ឋានប្រាសាទបុរាណ | អប្សរា | | 1.417 | | | |
| 28 | 3,5,6 | | TR-10 | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់ថែទាំផ្លូវ | រៀបចំបញ្ជីផ្លូវ និងបង្កើតប្រព័ន្ធត្រួតពិនិត្យលក្ខខ័ណ្ឌផ្លូវ | សាធារណការ និង អភិវឌ្ឍន៍ជនបទ | | 1.800 | | | |

## តារាង ៥ : គំរោង និងកម្មវិធីដែលបានស្នើឡើង (២/២)

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 29 | 4,5,6 | ទឹក | W-1 | ការត្រួតពិនិត្យប្រសិទ្ធភាពការ និងការបំពាក់នាឡិកាទឹក | ការចុះបញ្ជីអ្នកប្រើប្រាស់សំរាប់ពាណិជ្ជកម្ម និងការតម្លើងទឹកម៉ាស៊ីន | ខេត្ត | | 0 | | |
| 30 | 5,6 | | W-2 | អនុក្រឹត្យថ្នាក់ក្រសួងស្តីពីការយកតម្លៃប្រើប្រាស់ទឹកពីអណ្តូង | បង្កើតអនុក្រឹត្យស្តីពីការប្រើប្រាស់ទឹកអណ្តូង | ខេត្ត | | 0 | | |
| 31 | 4,5 | | W-3 | ប្តូរបំពង់ទឹកចាស់ | ប្តូរបំពង់ទឹកចាស់ (៦.៧ គីឡូម៉ែត្រ) ក្នុងតំបន់កណ្តាលក្រុង | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | អាទិភាព | 450 | | |
| 32 | 4,5 | | W-4 | សិក្ខាសាលាស្តីពីសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹក | រៀបចំការគ្រប់គ្រងធនធានទឹកតាមបែបសមាហរណកម្ម | ក្រសួងធនធានទឹក | អាទិភាព | 7.282 | | |
| 33 | 4,5 | | W-5 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ជំហាន ១ | បង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មី | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 13.716 | | |
| 34 | 4,5 | | W-6 | អភិវឌ្ឍធនធានទឹកនៅតាមរយៈការស្តារបារាយណ៍ | លើកកំពស់សមត្ថភាពបារាយណ៍ ការស្តារបារាយណ៍ឡើងវិញជាធនធានទឹក | ក្រសួងធនធានទឹក | | 8.320 | | |
| 35 | 4,5 | | W-7 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ជំហាន ២ | បង្កើតរោងចក្រប្រព្រឹត្តកម្មទឹក និងប្រព័ន្ធបែងចែកទឹក | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 12.310 | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 36 | 3,4,5,6 | សំណល់រឹង | SW-1 | អភិវឌ្ឍប្រព័ន្ធ/គ្រប់គ្រងសំណល់រឹងសមរម្យ | អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ និងស្ថាប័នសំរាប់គ្រប់គ្រងសំណល់រឹង | ក្រុមហ៊ុនសហប្រតិបត្តិការ - វិធីយោធាជុំ និងខេត្ត | | 1.000 | | |
| 37 | 3,4,5,6 | | SW-2 | ពង្រីកប្រព័ន្ធប្រមូលសំណល់ | ពង្រីកការប្រមូលសំណល់រឹងឱ្យបាន ១០០ % | ក្រុមហ៊ុនសហប្រតិបត្តិការ - វិធីយោធាជុំ និងខេត្ត | | 300 | | |
| 38 | 4,5,6 | | SW-3 | កន្លែងចាក់សំរាមអនាម័យ | លើកកំពស់ការអនុវត្តន៍នៅពេលកន្លែងចាក់សំរាមបច្ចុប្បន្ន និងផែនការសំរាប់កន្លែងថ្មី | ក្រុមហ៊ុនសហប្រតិបត្តិការ - វិធីយោធាជុំ និងខេត្ត | | 2.000 | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 39 | 3,4,5 | ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវ | SD-1 | គំរោងអភិវឌ្ឍន៍ទេសចរណ៍មេគង្គ១ | លើកកំពស់ប្រព័ន្ធបង្ហូរទឹកក្នុងក្រុង | សាធារណការ (ជំនួយADB) | | 11.988 | | |
| 40 | 3,4,5 | | SD-2 | គំរោងអភិវឌ្ឍន៍ក្រុងសៀមរាប | តម្លើងប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងតំបន់មណ្ឌលក្រុង | ខេត្ត និង សាធារណការ (ជំនួយ AFD) | អាទិភាព | 4.800 | | |
| 41 | 3,4,5 | | SD-3 | ប្រព័ន្ធបង្ហូរសំណល់រាវ ជំហាន ១ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងមណ្ឌលក្រុងភាគខាងលិច (តំបន់១) | ម. និងក្រសួងសាធារណការ | | 18.326 | | |
| 42 | 3,4,5 | | SD-4 | ប្រព័ន្ធបង្ហូរសំណល់រាវ ជំហាន ២ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងមណ្ឌលក្រុងភាគខាងកើត និងរោងចក្រប្រព្រឹត្តកម្មទឹក | ម. និងក្រសួងសាធារណការ | | 17.271 | | |
| 43 | 3,4,5 | | SD-5 | ការបង្ហូរទឹកភ្លៀង | ប្រព័ន្ធបង្ហូរទឹកក្នុងក្រុងថ្មីនៅភាគខាងលិច | ម. និងក្រសួងសាធារណការ | | 10.935 | | |
| 44 | 3,4,5 | | SD-6 | ការគ្រប់គ្រងសំណល់រាវ (ជំហាន ១) | រថយន្តប្រមូលសំណល់រាវ និងរោងប្រព្រឹត្តកម្មសំរាប់ (SD-1) | ម. និងក្រសួងសាធារណការ | | 1.614 | | |
| 45 | 3,4,5 | | SD-7 | ការគ្រប់គ្រងសំណល់រាវ (ជំហាន ២) | រថយន្តប្រមូលសំណល់រាវ និងរោងប្រព្រឹត្តកម្មសំរាប់ (SD-4) | ម. និងក្រសួងសាធារណការ | | 1.027 | | |
| 46 | 3,4,5 | | SD-8 | ការចោលសំណល់ បន្ទាប់ពីប្រព្រឹត្តកម្ម ជំហាន ១ | សំអួលប្រព័ន្ធបំពង់សំរាប់ប្រមូល និងនាំទឹកបន្ទាប់ពីធ្វើប្រព្រឹត្តកម្មទៅកាន់អាងបារាយណ៍ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 13.137 | | |
| 47 | 3,4,5 | | SD-9 | ការចោលសំណល់ បន្ទាប់ពីប្រព្រឹត្តកម្ម ជំហាន ២ | សំអួលប្រព័ន្ធបំពង់សំរាប់ប្រមូល និងនាំទឹកបន្ទាប់ពីធ្វើប្រព្រឹត្តកម្មទៅកាន់អាងបារាយណ៍ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 7.634 | | |
| 48 | 5,6 | ថាមពល | P-1 | ការបំពាក់ម៉ាស៊ីនភ្លើងម៉ាស៊ូតជាបន្ទាន់ | បំពាក់ម៉ាស៊ីនប្រើម៉ាស៊ូតថ្មី កំលាំងជាមេហ្គាវ៉ាត់ នៅទីតាំងអគ្គិសនីកម្ពុជា | អគ្គិសនីកម្ពុជា | អាទិភាព | 2.090 | | |
| 49 | 5 | | P-2 | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតបច្ចុប្បន្ន | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតឱ្យដល់កំរិត ១០ មេហ្គាវ៉ាត់ | អគ្គិសនីកម្ពុជា | | 20.800 | | |
| 50 | 5 | | P-3 | ពង្រីក និងបន្ថែមបណ្តាញចែកចាយ | បន្ថែមខ្សែដែលមានវ៉ុលទាប និងខ្ពស់ និងបន្ថែមអនុស្ថានីយ៍ និងនាឡិកាវាស់ម៉ោងថ្មីៗ | អគ្គិសនីកម្ពុជា | | 7.800 | | |
| 51 | 3,5 | | P-4 | បំពាក់ និងជួសជុលភ្លើងតាមផ្លូវ | កែលម្អភ្លើងតាមផ្លូវសំរាប់ភ្ញៀវទេសចរ | ស្រុក | | 780 | | |
| 52 | 1,3,6 | | P-5 | ប្រើប្រាស់អគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់អគារ និងក្រសាលផ្សេងៗ | បង្កើតរណើយផ្ទះអង្គរដោយប្រភពភ្លើងសាធារណៈ | អប្សរា / ស្ថាប័នពាក់ព័ន្ធ | | 330 | | |
| 53 | 2,5 | | P-6 | ធ្វើផែនការផ្គត់ផ្គង់អគ្គិសនីដល់កន្លែងដែលគ្មានអគ្គិសនី | ពង្រីកតំបន់មានអគ្គិសនី នៅពេលមានការពង្រីកក្រុង | អគ្គិសនីកម្ពុជា | | 275 | | |
| 54 | 5,6 | | P-7 | ជំនួយដល់ការកសាងសមត្ថភាពសំរាប់អគ្គិសនីកម្ពុជា | បណ្តុះបណ្តាលវិស្វករពីរអគ្គិសនីកម្ពុជានៅសៀមរាប | អគ្គិសនីកម្ពុជា | | 550 | | |
| 55 | 5,6 | | P-8 | ជំនួយដល់ការពិនិត្យឡើងវិញលើអត្រាថ្លៃភ្លើង | ផ្តល់អត្រាថ្លៃភ្លើងទៅតាមប្រភេទអ្នកប្រើប្រាស់ | អគ្គិសនីកម្ពុជា/ អាជ្ញាធរអគ្គិសនីកម្ពុជា | | 990 | | |
| 56 | 5,6 | | P-9 | ពិនិត្យឡើងវិញច្បាប់ បទបញ្ញា និងក្រឹត្យទាក់ទងអគ្គិសនីដើម្បីបន្ថយបន្ទុកបរិស្ថាន | ពិនិត្យ កែសំរួល និងបង្កើតច្បាប់ពាក់ព័ន្ធដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន | ក្រុង អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា | | 1.800 | | |
| 57 | 5,6 | | P-10 | អភិវឌ្ឍប្រភពថាមពលចិរភាព | ស្វែងរកជំរើសសំរាប់ប្រភពថាមពល | អគ្គិសនីកម្ពុជា ថាមពល | | 660 | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | (អនុសាសន៍) | | | | | | | |
| 58 | 6 | រដ្ឋបាលខេត្ត | L-1 | គណៈកម្មការអភិវឌ្ឍន៍សំរាប់អនុម័តគំរោង | បង្កើតគណៈកម្មការមួយសំរាប់ប្រតិបត្តិការរួមក្នុងខេត្ត | ខេត្ត | | 0 | | |
| 59 | 6 | | L-2 | អភិវឌ្ឍន៍ធនធានមនុស្សក្នុងខេត្ត | ការលើកកំពស់ចំណេះដឹងមន្ត្រីខេត្ត | ខេត្ត | | 1,600 | | |
| 60 | 6 | | L-3 | កំណែទំរង់ស្ថាប័ននៃអាជ្ញាធរខេត្តស.រ | ធ្វើឱ្យប្រសើរនូវការសម្របសម្រួលគ្រប់គ្រងនៅក្នុងខេត្ត | ខេត្តសៀមរាប | | | | |
| 61 | 6 | | L-4 | បង្កើត និងអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ឱ្យមានប្រសិទ្ធភាព | រៀបចំក្របខ័ណ្ឌច្បាប់សំរាប់រដ្ឋបាលឯកភាព | ខេត្ត ក្រសួងមហាផ្ទៃ | | | | |
| 62 | 6 | | L-5 | កំណែទំរង់ហិរញ្ញវត្ថុនៅថ្នាក់ខេត្តសំរាប់រដ្ឋបាលឯកភាព | ពង្រឹងធនធានហិរញ្ញវត្ថុរបស់ខេត្តសៀមរាប | ក្រសួងហិរញ្ញវត្ថុ សភាជាតិ | | | | |
| 63 | 3,6 | ការចូលរួមពីសហគមន៍ សហគមន៍ | C-1 | ធ្វើផែនទី ប្រើប្រាស់ដី | រៀបចំសិក្ខាសាលាដើម្បីធ្វើផែនទីក្នុងស្រុក | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 64 | 3,6 | | C-2 | ធ្វើផែនការសហគមន៍ | សិក្ខាសាលាធ្វើផែនការជាមួយភាគីពាក់ព័ន្ធនៅមូលដ្ឋាន | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 65 | 3,6 | | C-3 | សមាគមសហគមន៍ | សមាគមសហគមន៍ដើម្បីអនុវត្តគំរោង | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 66 | 2,3,6 | | C-4 | ការអនុវត្តការងារនៅតាមសហគមន៍ | អនុវត្តវិធីសាស្ត្រមជ្ឈការសំរាប់ធ្វើផែនការគំរោង | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 100 | | |
| 67 | 2,3,6 | | C-5 | ការត្រួតពិនិត្យអំពីការរស់នៅរួមគ្នារវាងអ្នកភូមិ និងទេសចរណ៍ | ផែនការសំរាប់តំបន់១ និង២របស់អប្សរាសំរាប់ឱ្យសហគមន៍អាចរស់នៅជាមួយនឹងបេតិកភណ្ឌ | អប្សរា ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 100 | | |
| 68 | 2,3,6 | | C-6 | ផែនការគ្រប់គ្រងអប្សរា និងការអភិវឌ្ឍន៍សហគមន៍ | លើកកំពស់ជីវភាពប្រជាជនដើម្បីរស់នៅសមរម្យជាមួយបេតិកភណ្ឌ | អប្សរា ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 3,000 | | |
| 69 | 3,6 | | C-7 | ស្វែងយល់ពីតម្រូវការរបស់ប្រជាជន | ប្រើប្រាស់ប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយសំលេងរបស់ប្រជាជន | ខេត្ត | | 1 | | |
| សរុប | | | | | | | | 310,633 | | |

## ៧. ការរៀបចំហិរញ្ញវត្ថុ និងស្ថាប័ន

ដើម្បីធ្វើឱ្យជោគជ័យលើផែនការដែលបានលើកឡើងក្នុងគំរោង/កម្មវិធី ក្រុមសិក្សាស្នើអនុសាសន៍មួយចំនួនក្នុងជំពូកអំពីការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុ សំរាប់រដ្ឋាភិបាលនៅថ្នាក់ខេត្ត និងក្រសួងនៅថ្នាក់ជាតិ ។

### ១. អនុសាសន៍សំរាប់ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត

ក. ធានាឱ្យមានការចែករំលែកព័ត៌មាន និងការយល់ដឹងរួមអំពីគោលនយោបាយ ផែនការ ថវិកា និងគំរោងនានាក្នុងស្រុកសៀមរាបរវាងសាលាខេត្ត មន្ទីរពាក់ព័ន្ធក្នុងខេត្ត និងអាជ្ញាធរអប្សរាក្នុងស្រុកសំរាប់ធ្វើឱ្យរលូននូវការសំរបសំរួល និងការធ្វើសេចក្តីសំរេចរបស់អភិបាលខេត្តអំពីសកម្មភាពអភិវឌ្ឍន៍

ខ. ធានាឱ្យមានអាជ្ញាធរជាក់លាក់មួយដើម្បីអនុញ្ញាត/ហាមឃាត់សកម្មភាពឯកជននៅក្នុងវិស័យជាអាទិភាពមួយចំនួន ដូចជា ការប្រើប្រាស់ដី និងការគ្រប់គ្រងសំណង់ ការត្រួតពិនិត្យបរិស្ថាន និងការប្រើប្រាស់ធនធានទឹក ទាំងទឹកក្រោមដី និងទឹកលើដី

គ. ពង្រឹងមុខងារសំរាប់បង្កើតគោលនយោបាយក្រុង និងការគ្រប់គ្រងក្រុង

ឃ. ពង្រឹងគំនិតផ្តួចផ្តើមរបស់ខេត្ត ដើម្បីធានាឱ្យមានការចូលរួមយ៉ាងមានប្រសិទ្ធភាពពីផ្នែកឯកជន ។

កត្តាដែលមិនអាចខ្វះបាននោះគឺត្រូវប្រើប្រាស់ការចូលរួមពីផ្នែកឯកជនជាមួយនឹងស្ថាប័ននៅថ្នាក់ខេត្ត ដែលបានពង្រឹងរួចហើយ ។

១) ពង្រឹងរដ្ឋបាលថ្នាក់ខេត្ត ដោយយកចិត្តទុកដាក់ទៅលើ :

- ធនធានមនុស្សលើជំនាញបច្ចេកទេស និងគ្រប់គ្រង
- មូលដ្ឋានហិរញ្ញវត្ថុ សំរាប់ចំណាយប្រតិបត្តិ និង
- មូលដ្ឋានទិន្នន័យ ដើម្បីសំរួលដល់ការត្រួតពិនិត្យការប្រើប្រាស់ដី បរិស្ថាន ការប្រើប្រាស់ទឹក និងសេវាកម្មសាធារណៈឱ្យមានប្រសិទ្ធភាព ។

២) លើកកំពស់ការរៀបចំឱ្យមានការចូលរួមពីផ្នែកឯកជន

ការរៀបចំឱ្យមានការចូលរួមពីផ្នែកឯកជនគួរធ្វើឡើង ដោយផ្អែកលើមូលដ្ឋានតម្លាភាព និងការប្រកួតប្រជែង ដើម្បីធានាភាពយុត្តិធម៌ គណនេយ្យភាព និងប្រសិទ្ធភាពនៃសេវាកម្មដែលបានផ្តល់ជូន ស្របតាមផែនការអភិវឌ្ឍន៍ចិរភាព។ វិស័យ ដែលបានស្នើឱ្យមានការចូលរួមពីផ្នែកឯកជនរួមមាន :

- ការប្រមូលសំណល់រឹង
- ការលើកកំពស់ការយល់ដឹងអំពីការកែលំអបរិស្ថាន
- ការផ្សព្វផ្សាយវិស័យទេសចរណ៍

## ២. អនុសាសន៍សំរាប់ក្រសួងនៅថ្នាក់ជាតិ

ក. បង្កើត និងបកស្រាយច្បាប់ លិខិតបទដ្ឋានច្បាប់ និងនីតិវិធីក្នុងផ្នែកសំខាន់ៗ ដូចជា ការគ្រប់គ្រងលើការប្រើប្រាស់ដីធ្លី និងបរិស្ថាន និងការគ្រប់គ្រងទឹក។

ខ. ពង្រឹងសមត្ថភាពបច្ចេកទេសរបស់ក្រសួង និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីជួយអភិបាលខេត្តប្រើប្រាស់គំនិតផ្តួចផ្តើមប្រកបដោយប្រសិទ្ធភាព ដោយសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងដីធ្លី បរិស្ថាន និងទឹក។

គ. គួរមានការកែទំរង់ពន្ធជាបន្ទាន់ សំរាប់ជួយដល់ការអភិវឌ្ឍន៍មូលដ្ឋាន រួមទាំងការអភិវឌ្ឍន៍ក្នុងស្រុកសៀមរាប។

## ៤. ការគិតគូរពីសង្គម និងបរិស្ថាន

ផែនការកាត់បន្ថយផលប៉ះពាល់មួយចាំបាច់ត្រូវបង្កើត ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គមដែលបណ្តាលមកពីការអនុវត្តនីគំរោងដែលបានស្នើឡើង។ ផែនការនេះបង្កើតឡើង សំរាប់អធិការកិច្ច និងការត្រួតពិនិត្យលើលក្ខខណ្ឌបរិស្ថាន ឬសង្គម និងវិធានការកាត់បន្ថយផលប៉ះពាល់ក្នុងអំឡុងពេលមុនសាងសង់ ក្នុងពេលសាងសង់ និងក្នុងពេលពេលប្រតិបត្តិ។ EIA/IEIA លើគំរោងនីមួយៗនៃគំរោងដែលបានស្នើឡើងនៅក្នុង ផែនការមេនេះត្រូវធ្វើឡើងក្នុងអំឡុងពេលសិក្សាលទ្ធភាពអនុវត្តគំរោង និងគំរោងលំអិត ប្រសិនមានតំរូវការពីក្របខ័ណ្ឌស្របច្បាប់លើលក្ខខណ្ឌបរិស្ថាន និងសង្គមក្នុងប្រទេសកម្ពុជា។

### ១) អំឡុងពេលមុនការសាងសង់

- ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ
- ការជ្រើសរើសទីកន្លែងដោយប្រុងប្រយ័ត្នសំរាប់គំរោងនីមួយៗ
- ការអង្កេតបុរាណវត្ថុ
- ការធានាជំរើសការងារសំរាប់ម្ចាស់ដីក្នុងតំបន់គំរោង
- ការធ្វើពិសោធន៍សាកល្បងនូវគុណភាពទឹកក្រោមដី
- ការអង្កេតភូគព្ភសាស្ត្រជលសាស្ត្រ
- ការសំរបសំរួលអន្តរក្រសួងលើការប្រើប្រាស់ទឹក
- ការអង្កេតភូគព្ភសាស្ត្រលើដី
- ការអង្កេតបរិយាកាស

## ២) អំឡុងពេលនៃការសាងសង់

### ១. វិធានការកាត់បន្ថយផលប៉ះពាល់ពីសកម្មភាពសាងសង់

- ការគ្រប់គ្រងសម្ភារៈសំណង់ឱ្យបានសមរម្យ
- ការបាញ់ទឹកលើផ្លូវថ្នល់
- ការថែទាំសម្ភារៈសំណង់ និងយានយន្តឱ្យបានសមរម្យ
- ការគ្រប់គ្រងទឹកពីការដ្ឋានសំណង់
- ការបង្កើតប្រព័ន្ធប្រមូលសំណល់សំណង់
- ការកំណត់ពេល / ការធ្វើផែនការ / ការគ្រប់គ្រងការសាងសង់ឱ្យបានសមរម្យ
- ការបំពាក់ជញ្ជាំងខ្ទប់សំលេង ឬតំបន់ទ្រនាប់

### ២. នីតិវិធីសមរម្យសំរាប់ស្រាវជ្រាវបុរាណវត្ថុ

ម្ចាស់កិច្ចសន្យាសាងសង់ត្រូវបញ្ឈប់សកម្មភាពសាងសង់ជាបន្ទាន់ ប្រសិនបើមានការរាយការណ៍ពីការប្រទះឃើញវត្ថុបុរាណ។ បើចាំបាច់ អ្នកបុរាណវិទូត្រូវធ្វើការអង្កេតពីវត្ថុបុរាណនោះ ហើយចាំបាច់ត្រូវចាត់វិធានការសមស្របដើម្បីសង្គ្រោះ។

### ៣. ការកែប្រែតំបន់រងការប៉ះពាល់ដោយការសាងសង់ទៅភាពល្អូណៈដើមវិញ

គ្រប់កន្លែងដែលរងផលប៉ះពាល់ដោយសារការអនុវត្តគំរោងចាំបាច់ត្រូវស្តារឡើងវិញឱ្យដូចភាពដើម បន្ទាប់ពីបញ្ចប់ការសាងសង់។ សម្ភារៈ គ្រឿងចក្រ និងយានយន្តសំរាប់ការសាងសង់ត្រូវប្រមូលចេញ ហើយសំណល់ពីការសាងសង់ សម្ភារៈមិនប្រើប្រាស់ និងដីកខ្វក់ចាំបាច់ត្រូវយកទៅចោលឱ្យបានសមស្រប។

## ៣) អំឡុងពេលប្រតិបត្តិ

ចាំបាច់ត្រូវពិចារណា និងអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់នានាក្នុងអំឡុងពេលនៃការអនុវត្តនីគំរោងនីមួយៗ។ វិធានការទាំងនេះត្រូវពិចារណា និងបង្កើតនៅកំរិតផែនការមេ ឬកំរិតសិក្សាលទ្ធភាពអនុវត្តគំរោង ដោយសារសេចក្តីលំអិតនៃគំរោងនីមួយៗមិនត្រូវបានបញ្ជាក់ច្បាស់លាស់នៅដំណាក់កាលនេះទេ។ វិធានការកាត់បន្ថយផលប៉ះពាល់ ដែលបានពិចារណានៅដំណាក់កាលនេះសំរាប់គំរោងមួយចំនួន ត្រូវបានពិពណ៌នាដូចខាងក្រោម :

- កន្លែងកប់សំរាម : ប្រមូលឧស្ម័នពីកន្លែងចាក់សំរាម ប្រើដីសំរាប់គ្របកន្លែងចាក់សំរាមរៀងរាល់ថ្ងៃដើម្បីការពារក្លិនស្អុយ និងកាត់បន្ថយឱ្យដល់កំរិតអប្បបរមានូវអគ្គីភ័យកើតឡើងដោយឯងឡនៅកន្លែងចាក់សំរាម និងអាងប្រព្រឹត្តិកម្ម ដើម្បីធ្វើប្រព្រឹត្តិកម្មទឹកសំណល់ពីកន្លែងកប់សំរាម។
- អាងប្រព្រឹត្តិកម្មសំណល់ : ថែទាំជាប្រចាំដើម្បីការពារក្លិនស្អុយ
- ម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត : តម្លើងឧបករណ៍ដើម្បីកាត់បន្ថយការបំភាយផ្សែង
- ការបូមទឹកក្រោមដី : ត្រួតពិនិត្យជាបណ្តើរៗនូវការបាក់ស្រុតដី

## ៩. អនុសាសន៍

១. រហូតមកដល់ពេលនេះ សៀមរាបបានឆ្លងកាត់ទេសចរណ៍បែបគំហុក ។ ទេសចរណ៍បែបគំហុកនេះបានកើតមានឡើងនៅតាមតំបន់ទេសចរណ៍ និងសកម្មភាពកំសាន្តតិចតួចប៉ុណ្ណោះក្រៅពីបរិវេណអង្គរ ។ សេវាកម្មសាធារណៈសំខាន់ៗមិនអាចឆ្លើយតបទៅនឹងការអភិវឌ្ឍន៍សណ្ឋាគារយ៉ាងឆាប់រហ័យ ។ គេយល់ឃើញថា ក្រុងសៀមរាបពុំទាន់មានសុវត្ថិភាព ស្អាត ឬមានភាពងាយស្រួលសំរាប់ឱ្យភ្ញៀវទេសចរបុគ្គល ឬគ្រួសារដើម្បីដើរកំសាន្តនៅឡើយ ។ អ្នកបង្កើតគោលនយោបាយគួរយល់ថា ការអភិវឌ្ឍន៍ទេសចរណ៍ និងក្រុងដូចនេះមិនអាចមាននិរន្តរភាពឡើយនៅពេលអនាគត ។ គេគួរតែកែប្រែពីទេសចរណ៍បែបបរិមាណទៅជាទេសចរណ៍គុណភាព និងគួរតែធ្វើឡើងឱ្យស្របទៅនឹងលក្ខខណ្ឌបរិស្ថានធម្មជាតិ ។ រដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ខ្ពស់ក្នុងការកំណត់ឱ្យបានច្បាស់លាស់នូវបញ្ហាក្រុង និងបរិស្ថានក្នុងសៀមរាប ។ម្យ៉ាងវិញទៀត ការធ្លាក់ចុះខាងបរិស្ថាន និងការខូចខាតដែលអាចកើតមានដល់ក្រុងអាចធ្វើឱ្យភ្ញៀវទេសចរចេញពីសៀមរាប នៅពេលមានការប្រកួតប្រជែងកើតខ្ពស់ពីតំបន់ទេសចរណ៍ផ្សេងៗទៀតនៅលើពិភពលោក ។

២. កត្តាដ៏សំខាន់បំផុតមួយគឺទឹកសំរាប់ភ្ញៀវទេសចរ ប្រជាជនមូលដ្ឋាន និងសំរាប់ដីកសិកម្មដែលអាចប្រើជាខ្សែក្រវ៉ាត់បៃតង ។ ការបូមទឹកក្រោមដីរបស់បុគ្គលសំរាប់បំរើគោលបំណងពាណិជ្ជកម្មគួរចុះបញ្ជី ត្រួតពិនិត្យ និងបង់ប្រាក់ នៅពេលចាំបាច់ ។ នៅពេលបច្ចុប្បន្ន ការងារនេះអាចអនុវត្តបាន បន្ទាប់ពីមានប្រព័ន្ធគ្រប់គ្រងទឹកស្អាតក្នុងក្រុង ។ គួររៀបចំផែនការសំរាប់ខេត្តទាំងមូលឱ្យបានលឿនបំផុត បើអាចធ្វើបានដើម្បីគ្រប់គ្រងធនធានទឹកដែលមានស្រាប់ និងដែលមានសក្ដានុពល និងសំរបសំរួលឱ្យមានការប្រើប្រាស់ទឹករយៈពេលយូរអង្វែង ។

៣. ការគ្រប់គ្រងលើការប្រើប្រាស់ដីគឺជាផ្នែកដ៏សំខាន់មួយទៀត ។ ការអភិវឌ្ឍន៍ក្រុងគួរតែអនុវត្តតែនៅក្នុងតំបន់ពង្រីកក្រុងដែលបានស្នើឡើង ។ អាស្រ័យហេតុនេះ ត្រូវផ្ដល់ហេដ្ឋារចនាសម្ព័ន្ធក្រុងឱ្យបានគ្រប់គ្រាន់ ។ គេអាចការពារតំបន់ប្រវត្តិសាស្ត្រ និងដីកសិកម្មពីការពង្រីកក្រុងដោយគ្មានការត្រួតពិនិត្យត្រឹមត្រូវ ។ នៅពេលមានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទាន់ពេលវេលា គេអាចបញ្ចៀសដីសាធារណៈពីការសាងសង់ ការតាំងទីលំនៅ និងការកាន់កាប់ដីខុសច្បាប់ដោយមានការចូលរួមពេញលេញពីប្រជាជនងាយរងគ្រោះក្នុងសង្គម ។ ការបង្កើតរចនាសម្ព័ន្ធរដ្ឋបាលបែបស្មុគស្មាញនាពេលបច្ចុប្បន្នសំរាប់ការធ្វើផែនការប្រើ ប្រាស់ដីធ្លីគួរតែសំរួលដើម្បីឱ្យការគ្រប់គ្រងដីធ្លីមានប្រសិទ្ធភាព ។

៤. ផែនការមេរយៈពេលវែងនេះគឺជាឯកសារមានជីវិត ។ ឯកសារនេះគួរតែពិនិត្យកែលំអដើម្បីឱ្យឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួល ជាពិសេសដោយខេត្តសៀមរាប អាជ្ញាធរអប្សរា គណៈកម្មការអភិវឌ្ឍន៍កម្ពុជា និងការិយាល័យនៃទីស្ដីការរដ្ឋមន្ត្រី ។ គំរោងអាទិភាពដែលបានស្នើឡើងគួរធ្វើការពិនិត្យឱ្យបានល្អិតល្អន់ដើម្បីធ្វើការរៀបចំ និងអនុវត្តឱ្យទាន់ពេលវេលា ។ ផ្ទុយផ្សំជាមួយនឹងកិច្ចខិតខំទាំងនេះ អាជ្ញាធរខេត្តគួរពង្រឹងមុខងាររបស់ខ្លួនដើម្បីពិនិត្យតាមដានការវិនិយោគ ការប្រើប្រាស់ដី គំរោងបរិស្ថានរបស់រដ្ឋាភិបាល និងពិនិត្យកែប្រែផែនការមេនេះ ។

៥. គំរោងសាកល្បង ដែលមានឈ្មោះ " ការធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង" និង "ការតាំងពិព័រណ៍ផលិតផលអង្គរ ឆ្នាំ២០០៥" បានទទួលជោគជ័យ ដោយសារគំនិតផ្ដួចផ្ដើមដ៏រឹងមាំរបស់មូលដ្ឋាន និងការគាំទ្រពីថ្នាក់ជាតិយ៉ាងទូលំទូលាយ ។ គំរោងទាំងនោះគួរចាត់ទុកជាគំរោងគំរូសំរាប់បន្តសកម្មភាពលើកកំពស់បរិស្ថានក្រុង និង

ពង្រីកឱ្យបានច្រើននូវផលប្រយោជន៍សេដ្ឋកិច្ចនៅមូលដ្ឋាន និងសោភ័ណភាពនៅជនបទ។ គំនិតផ្តួចផ្តើមនៅមូលដ្ឋានដែលអនុវត្តដោយអភិបាលខេត្តគួរតែទទួលបានការជ្រោមជ្រែងជាបន្តពីក្រសួងពាក់ព័ន្ធ ផ្នែកឯកជន និងប្រជាជននៅមូលដ្ឋាន ។

៦. ការកសាងសមត្ថភាពនៃអាជ្ញាធរនៅថ្នាក់មូលដ្ឋាន ជាពិសេសអាជ្ញាធរខេត្តគឺជាផ្នែកដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍សៀមរាបប្រកបដោយនិរន្តរភាព ។អាជ្ញាធរខេត្តគួរពង្រឹងមន្ត្រីធ្វើផែនការរបស់ខ្លួនជាបន្ទាន់នូវជំនាញបច្ចេកទេស ។ ខេត្តគួរលើកកំពស់ការចែករំលែកព័ត៌មានអំពីការអភិវឌ្ឍន៍រវាងមន្ទីរ និងអាជ្ញាធរផ្សេងៗនៅថ្នាក់ខេត្តតាមរយៈការបង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត។ ជាលទ្ធផល ខេត្តនឹងអាចក្លាយជាស្ថាប័នមួយដូចជាក្រុមប្រឹក្សាអភិវឌ្ឍន៍ខេត្ត ឬគណៈកម្មការគ្រប់គ្រងខេត្ត។ ខេត្តគួរមានកញ្ចប់ថវិកា ជាពិសេសសំរាប់ថែទាំសេវាកម្មសាធារណៈជាយុទ្ធសាស្ត្រផ្សេងៗ ដូចជា ផ្លូវថ្នល់ ការប្រមូលសំណល់ និងប្រព័ន្ធបង្ហូរទឹកភ្លៀង ។ ប្រភពហិរញ្ញវត្ថុដែលអាចទទួលបាន និងមានចំនួនច្រើនគឺបានមកពីចំណែកនៃថវិកាចូលទស្សនារមណីយដ្ឋានអង្គរ ។

៧. ខុសពីខេត្តផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ខេត្តសៀមរាបពឹងផ្អែកយ៉ាងខ្លាំងទៅលើវិស័យទេសចរណ៍ និងក្រុង ។ ដូចនេះ អាជ្ញាធរខេត្តសៀមរាបគួរពង្រឹងអំណាចក្នុងការធ្វើសេចក្តីសំរេចចិត្ត និងសមត្ថភាពបច្ចេកទេសសំរាប់ធ្វើផែនការត្រួតពិនិត្យ និងថែរក្សាបរិស្ថានក្រុង ។ អំណាចក្នុងការធ្វើសេចក្តីសំរេចរបស់ខេត្ត និងសមត្ថភាពបច្ចេកទេសគួរតែមានប្រសិទ្ធភាពដោយមានការគាំទ្រខាងបច្ចេកទេស និងច្បាប់ពីក្រសួង និងមន្ទីរពាក់ព័ន្ធព្រមទាំងមានការគាំទ្រពីអាជ្ញាធរអប្សរា ។

៨. រមណីយដ្ឋានអង្គរគឺជានិមិត្តរូបនៃអត្តសញ្ញាណជាតិ ជាបេតិកភណ្ឌវប្បធម៌ពិភពលោក និងជាប្រភពដ៏សំខាន់នៃរូបិយវត្ថុបរទេស ។ ដូចនេះ សៀមរាបគួរតែជាក្រុងគំរូលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា ។ សៀមរាមមិនត្រឹមតែមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពប៉ុណ្ណោះទេ តែថែមទាំងធ្វើការឆ្លុះបញ្ចាំងពីគតិបណ្ឌិតសម័យអង្គរលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ឆ្លុះបញ្ចាំងពីវប្បធម៌សម្បូរបែប និងការចូលរួមរបស់ប្រជាជន ក្នុងសកម្មភាពអភិវឌ្ឍន៍ក្នុងសតវត្សទី២១ ។ សៀមរាបមិនត្រឹមតែជាទីតាំងនៃរមណីយដ្ឋានរូបវន្តប៉ុណ្ណោះទេ តែថែមទាំងជាប្រភពព្រលឹងសកលដែលកំពុងត្រូវសាយភាយទៅកាន់កន្លែងផ្សេងៗទៀតក្នុងពិភពលោក ។ សៀមរាបក៏ជាកន្លែងទាក់ទាញខាងវប្បធម៌យ៉ាងខ្លាំងនៅតំបន់អាស៊ីអាគ្នេយ៍ ។ ដើម្បីធ្វើឱ្យសំរេចនូវគំនិតទាំងនេះគ្រប់ក្រសួង អាជ្ញាធរ និងក្រុមប្រឹក្សានៃរដ្ឋាភិបាលថ្នាក់ជាតិគួរចែករំលែកការយល់ដឹងរួម ដែលជាកត្តាសំខាន់សំរាប់ជួយសៀមរាបទាំងហិរញ្ញវត្ថុ និងបច្ចេកទេស ជាពិសេសលើការកែលំអបរិស្ថាន និងក្រុង ។

## ១. សេចក្តីផ្តើម

ស្រុកសៀមរាបដែលជាមជ្ឈមណ្ឌលនៃខេត្តសៀមរាប គឺជាទីតាំងនៃប្រាសាទអង្គរដែលជាបេតិកភណ្ឌពិភពលោក។ ស្រុកនេះមានសក្តានុពលដ៏អស្ចារ្យសំរាប់ការអភិវឌ្ឍន៍។ ចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិកាន់តែច្រើនឡើង បានមកទស្សនាបេតិកភណ្ឌវប្បធម៌អង្គរ ដែលជាសម្បត្តិទេសចរណ៍ដ៏សំខាន់របស់ប្រទេសកម្ពុជា។ មានចំនួនអ្នកទេសចរ ៧៥០.០០០ នាក់នៅឆ្នាំ២០០៤។ ដោយសារកំណើនយ៉ាងឆាប់រហ័សនៃចំនួនភ្ញៀវទេសចរនេះហើយ ទើបសណ្ឋាគារ ភោជនីយដ្ឋាន និងកន្លែងសំរាប់បំរើភ្ញៀវទេសចរថ្មីៗមួយចំនួនត្រូវបាន និងកំពុងសាងសង់នៅក្នុងក្រុងសៀមរាប/អង្គរ យ៉ាងអនាធិបតេយ្យ។ ជាមួយគ្នានេះដែរ ស្រុកសៀមរាបមានកំណើនប្រជាជនយ៉ាងលឿនផងដែរ។ ស្រុកមានប្រជាជន ប្រហែល៣០.០០០នាក់ នៅឆ្នាំ១៩៧៥ ចំនួន ៨៥.០០០ នាក់នៅឆ្នាំ១៩៩៣ និង១៣៩.០០០ នាក់ នៅឆ្នាំ២០០៤។

ការកើនឡើងនៃតំរូវការសេវាកម្មសាធារណៈត្រូវបានគេសង្កេតឃើញថាកំពុងតែហួសពីសមត្ថភាពនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈបច្ចុប្បន្ន ដូចជា ការផ្គត់ផ្គង់ទឹក ប្រព័ន្ធលូ អគ្គិសនី និងផ្លូវថ្នល់ជាដើម។ កង្វះខាតក្នុងការផ្តល់សេវាកម្មសាធារណៈមានសភាពធ្ងន់ធ្ងរ ជាពិសេសផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលទាក់ទងនឹងបរិស្ថាន ដូចជាប្រព័ន្ធបង្ហូរសំណល់រាវ និងការចោលសំណល់រឹង។ ការផ្គត់ផ្គង់សេវាកម្មបែបនេះឱ្យមានស្ថិរភាព និងការថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈឱ្យបានត្រឹមត្រូវទាមទារនូវក្របខ័ណ្ឌស្ថាប័នសមស្រប និងសមត្ថភាពគ្រប់គ្រង។

នៅក្នុងន័យនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានទទួលស្គាល់នូវតំរូវការដ៏ចាំបាច់ក្នុងការធ្វើផែនការមេរួមមួយ ដើម្បីអភិវឌ្ឍវិស័យសេដ្ឋកិច្ច សាងសង់ហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ និងរក្សាគុណភាពបរិស្ថាន និងធនធានទេសចរណ៍នៅក្នុងក្រុងសៀមរាប/អង្គរតាមចក្ខុវិស័យយូរអង្វែង។

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា និងJICA បានឯកភាពគ្នាលើវិសាលភាពនៃការសិក្សាផែនការមេរួម សំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គរនៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយនិរន្តរភាព។

JICA បានប្រគល់ការសិក្សានេះដល់ក្រុមសិក្សាមួយដែលរៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសជប៉ុន (IDCJ) ក្រុមហ៊ុន Nippon Koei Co. Ltd. (NK) និងក្រុមហ៊ុន Kukusai Kogyo Co. Ltd. (KKC)។

ក្រុមសិក្សាបានចាប់ផ្តើមសិក្សានៅខែវិច្ឆិកា ឆ្នាំ២០០៤ និងបញ្ចប់នៅខែមីនា ឆ្នាំ២០០៦។ របាយការណ៍ចុងក្រោយនេះនឹងស្នើឡើងនូវផែនការមេ និងគំរោងអាទិភាពមួយចំនួន។

### ១.១ គោលបំណងនៃការសិក្សា

ការសិក្សានេះមានគោលបំណងដើម្បី :

(1) រៀបចំផែនការមេរួមមួយ សំរាប់ការអភិវឌ្ឍន៍ក្រុងសៀមរាប/អង្គររយៈពេលវែងប្រកបដោយនិរន្តរភាពដើម្បីធ្វើឱ្យសំរេចនូវតុល្យភាពដ៏សមស្របមួយរវាងឧស្សាហកម្មទេសចរណ៍ បរិស្ថានក្រុង និងសមត្ថភាពស្ថាប័ន

(2) ស្នើវិធានការមួយចំនួនក្នុងគោលដៅជំរុញ និងពង្រីកសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការអភិវឌ្ឍន៍ទេសចរណ៍ និង

(3) លើកកំពស់ការផ្ទេរបច្ចេកទេសឱ្យសមភាគីកម្ពុជា ដើម្បីពង្រឹងសមត្ថភាពស្ថាប័នរដ្ឋាភិបាលមូលដ្ឋាន និងសហគមន៍។




រូបទី ២ : គោលបំណងនៃការសិក្សា

### ១.២ តំបន់សិក្សា

តំបន់សិក្សាគ្របដណ្តប់ស្រុកសៀមរាបដោយយកចិត្តទុកដាក់លើតំបន់ក្រុង និងពង្រីកទៅកាន់តំបន់ពាក់ព័ន្ធផ្សេងទៀតនៃស្រុកសៀមរាបដោយមានគោលដៅសិក្សាសេដ្ឋកិច្ចមូលដ្ឋាន ។

### ១.៣ ដំណើរការនៃការសិក្សា

## ១. រចនាសម្ព័ន្ធនៃក្រុមសិក្សា

អាជ្ញាធរខេត្តសៀមរាប និងអាជ្ញាធរអប្សរាគឺជាទីភ្នាក់ងារអនុវត្តការងារជាមួយក្រុមសិក្សារបស់JICA ។ សមភាគីចំនួន១៣នាក់មកពីអាជ្ញាធរខេត្តសៀមរាប និងអាជ្ញាធរអប្សរាត្រូវជ្រើសតាំងឱ្យចូលរួមនៅក្នុងក្រុមសិក្សា។ ពួកគេគឺជាជនបង្គោលតំណាងមន្ទីរ/ផ្នែកដែលពាក់ព័ន្ធ ។

កិច្ចប្រជុំជាបន្តបន្ទាប់ត្រូវបានរៀបចំឡើង ដើម្បីធ្វើឱ្យរលូននូវការអនុវត្តនៃការសិក្សា និងធ្វើឱ្យបានលទ្ធផលល្អ ។ កិច្ចប្រជុំអន្តរក្រសួង និងគណៈកម្មាធិការដឹកនាំត្រូវបានរៀបចំឡើងសំរាប់ការសិក្សានេះ ។ លើសពីនេះ កិច្ចប្រជុំភាគីពាក់ព័ន្ធ ដូចជាសង្គមស៊ីវិល ផ្នែកឯកជន និងNGOs ត្រូវបានធ្វើឡើងដើម្បីផ្លាស់ប្តូរគំនិតយោបល់ ។




រូបទី ៣ : រចនាសម្ព័ន្ធស្ថាប័ន

## ២. យន្តការសំរបសំរួលសំរាប់ការសិក្សា

កិច្ចប្រជុំអន្តរក្រសួងនៅថ្នាក់ជាតិត្រូវបានរៀបចំឡើង ដើម្បីចែករំលែកព័ត៌មាន និងសំរាប់ពង្រឹងការងារសំរបសំរួលរវាងក្រសួងពាក់ព័ន្ធ ។ គណៈកម្មការដឹកនាំការសិក្សានៅថ្នាក់ខេត្តត្រូវបានបង្កើតឡើង ដើម្បីពិគ្រោះយោបល់ជាមួយក្រុមសិក្សាប្រយោជន៍ដោយមានគោលដៅធានាឱ្យមានភាពរលូននូវការអនុវត្តន៍ការសិក្សា និងប្រើប្រាស់លទ្ធផលនៃការសិក្សាឱ្យមានប្រសិទ្ធភាព ។

## ៣. ដំណើរការនៃការចូលរួមរបស់ប្រជាជន

ការសិក្សានេះបានប្រើប្រាស់វិធីសាស្ត្រដោយមានការចូលរួមពីប្រជាជនតាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ ។ ការចូលរួមទាំងនេះធ្វើឡើងតាមរយៈកិច្ចប្រជុំភាគីពាក់ព័ន្ធចំនួន៤ដង ។ នៅក្នុងកិច្ចប្រជុំទីមួយ១ ក្រុមសិក្សាJICA បានធ្វើបទបង្ហាញពីគំនិត និងខ្លឹមសារនៃរបាយការណ៍ទីមួយ១ និងស្នើឱ្យមានការពិភាក្សាទូលំទូលាយ ដើម្បីកែលំអរបាយការណ៍ទាំងនោះ ។ ខាងក្រោមនេះគឺជាតារាងសង្ខេបនៃកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ។

តារាង ៦ : តារាងសង្ខេបនៃកិច្ចប្រជុំភាគីពាក់ព័ន្ធ

| | កាលបរិច្ឆេទ | របាយការណ៍សំរាប់ការពិភាក្សា | ចំនួនអ្នកចូលរួម | អ្នកចូលរួម |
|---|---|---|---|---|
| ទីមួយ | ៣ កុម្ភៈ ២០០៥ | របាយការណ៍ចាប់ផ្តើម | ១៩៤ | មន្ត្រី អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន ទីភ្នាក់ងារទេសចរណ៍ អ្នកផ្តល់ជំនួយ និងអ្នកដឹកនាំសហគមន៍ |
| ទីពីរ | ១០ មីនា ២០០៥ | របាយការណ៍រីកចំរើន | ៦៧ | |
| ទីបី | ២២ វិច្ឆិកា ២០០៥ | របាយការណ៍បណ្តោះអាសន្ន | ១០០ | |
| ទីបួន | ៣១ មករា ២០០៦ | ពង្រាងរបាយការណ៍ចុងក្រោយ | ២០០ | |





រូបថតនៃកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ លើកទី១ រូបថតនៃកិច្ចពិភាក្សាតាមក្រុមក្នុងកិច្ចប្រជុំភាគីពាក់ព័ន្ធលើកទី២

ក្រៅពីកិច្ចប្រជុំភាគីពាក់ព័ន្ធ ក្រុមសិក្សាបានរៀបចំឱ្យមានសិក្ខាសាលាជាច្រើននៅថ្នាក់ភូមិ និងឃុំជាញឹកញាប់ ដើម្បីផ្លាស់ប្តូរគំនិតយោបល់ជាមួយប្រជាជននៅមូលដ្ឋាន ។

## ៤. ក្របខ័ណ្ឌពេលវេលានៃការសិក្សា

ក្រុមសិក្សាធ្វើការសិក្សានៅក្នុងអំឡុងពេលពីខែវិច្ឆិកា ឆ្នាំ២០០៤ ដល់ខែមីនា ឆ្នាំ២០០៦។ ការសិក្សានេះបានបែងចែកជាបួនដំណាក់កាល ដូចមានបង្ហាញនៅក្នុងរូបខាងក្រោម ។

<u>ដំណាក់កាលទី I</u>

ការយកចិត្តទុកដាក់សំខាន់នៅក្នុងដំណាក់កាលនេះ គឺការវិភាគដើម្បីកំណត់បញ្ហាគន្លឹះក្នុងក្រុងសៀមរាប/អង្គរ ។ ក្រុមសិក្សាបង្ហាញពីរចនាសម្ព័ន្ធនៃចំណោទបញ្ហា និងបញ្ហាក្នុងក្រុងសៀមរាប/អង្គរ នៅឯកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរគំនិតយោបល់នៅខែកុម្ភៈ ឆ្នាំ២០០៥។ លទ្ធផលនៃដំណាក់កាលទី ១ នេះត្រូវបានចងក្រងនៅក្នុងរបាយការណ៍សកម្មភាពរីកចំរើនទី១ ។

<u>ដំណាក់កាលទី II</u>

លទ្ធផលដ៏សំខាន់មួយពីដំណាក់កាលទីII គឺចក្ខុវិស័យជាយុទ្ធសាស្ត្រសំរាប់អភិវឌ្ឍក្រុងសៀមរាប/អង្គរប្រកបដោយនិរន្តរភាព ។

កិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធលើកទី២ត្រូវបានធ្វើឡើងនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៥ ។ កិច្ចប្រជុំនេះមានគោល-បំណងពន្យល់សេណារីយ៉ូទាំង២ និងចក្ខុវិស័យជាយុទ្ធសាស្ត្រដែលបានរៀបចំឡើងដោយក្រុមសិក្សា និងស្វែងរកគំនិតកែលំអពីភាគីពាក់ព័ន្ធទាំងនោះ ។

ក្រុមសិក្សាបានចងក្រងរបាយការណ៍សកម្មភាពរីកចំរើនទី២ ដែលជាលទ្ធផលនៃការសិក្សាក្នុងដំណាក់កាលទី២ ។




**កំណត់ចំណាំ :** DICR: ពង្រាងរបាយការណ៍ដំបូង ICR: របាយការណ៍ដំបូង PR1: របាយការណ៍រីកចំរើនទី១ PR2: របាយការណ៍រីកចំរើនទី២ ITR: របាយការណ៍បណ្តោះអាសន្ន DFR: សេចក្តីព្រាងរបាយការណ៍ចុងក្រោយ FR: របាយការណ៍ចុងក្រោយ ។

រូបទី ៤ : ក្របខ័ណ្ឌពេលវេលានៃការសិក្សា

ដំណាក់កាលទី III

ពង្រាងផែនការមេដែលជាលទ្ធផលនៃដំណាក់កាលទីពារួមត្រូវបានរៀបចំឡើង ។ ផែនការនេះរួមមានពីរភាគ ។ ភាគទី១ គឺជាពង្រាងផែនការមេ និងភាគទី២គឺជាផែនការអភិវឌ្ឍន៍តាមវិស័យ ។ ភាគទី១ ពិពណ៌នាពីផែនការរួមមួយសំរាប់អភិវឌ្ឍខេត្តសៀមរាប និងភាគទី ២រៀបរាប់លំអិតអំពីផែនការទៅតាមវិស័យនីមួយៗ ។

ម្យ៉ាងទៀត គំរោងសាកល្បងពីរខាងក្រោមត្រូវបានរៀបចំឡើងដើម្បីចងក្រងលទ្ធផលសំរាប់ដាក់បញ្ចូលទៅក្នុងផែនការមេ ។ គំរោងសាកល្បងទាំងពីរនោះគឺ :

គំរោងសាកល្បងទី១ : ធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង

គំរោងសាកល្បងទី២ : ការតាំងពិព័រណ៍ផលិតផលអង្គរ

នៅក្នុងផ្នែកមួយនៃគំរោងសាកល្បង "ធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង" យុទ្ធនាការបរិស្ថានត្រូវបានធ្វើឡើងប្រកបដោយជោគជ័យនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ដោយមានប្រជាជនចូលរួមចំនួន១០០០ នាក់ ក្រោមការដឹកនាំរបស់អភិបាលខេត្តសៀមរាប ។ ការតាំងពិព័រណ៍ផលិតផលអង្គរត្រូវបានរៀបចំឡើងពីថ្ងៃទី៩ ដល់១១ ខែធ្នូ ឆ្នាំ ២០០៥ ក្នុងគោលបំណងផ្សព្វផ្សាយផលិតផលក្នុងស្រុក និងមានភ្ញៀវចូលទស្សនាសរុបប្រមាណជា ១០.០០០ នាក់ ។

ដំណាក់កាលទី IV

ផែនការមេត្រូវបានរៀបចំឡើងក្នុងដំណាក់កាលទី៤ ។ កិច្ចប្រជុំអន្តរក្រសួង ដែលជាកិច្ចប្រជុំចុងក្រោយបានធ្វើឡើងនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៦ ដើម្បីធ្វើបទបង្ហាញពីលទ្ធផលនៃពង្រាងរបាយការណ៍ និងស្នើឱ្យផ្តល់គំនិតកែលំអ

ដែលមានអ្នកចូលរួមចំនួន ១៥០ នាក់ ។ របាយការណ៍ចុងក្រោយនេះត្រូវបានចងក្រងឡើងដោយផ្អែកទៅលើគំនិតកែលំអពីសិក្ខាសាលានេះ ។

## ១.៨ រចនាសម្ព័ន្ធរបាយការណ៍ចុងក្រោយ

រចនាសម្ព័ន្ធរបាយការណ៍មានបង្ហាញនៅក្នុងរូបខាងក្រោម ។




**រូបទី ៥ : រចនាសម្ព័ន្ធរបាយការណ៍ (១)**




**រូបទី ៦ : រចនាសម្ព័ន្ធ របាយការណ៍ (២)**

ទំរង់រូមនៃផែនការមេនេះមានបង្ហាញក្នុងតារាងខាងក្រោម។

**តារាង ៧ : ទំរង់រួមនៃផែនការមេ**

